ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

**របាយការណ៍៖**

# វេទិកាថ្នាក់ជាតិលើកទី ៨ ស្តីពីការអប់រំបរិយាបន្ន

“បង្កើនការវិនិយោគលើការកសាងសមត្ថភាពគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនអំពីការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព”




ថ្ងៃពុធ ទី១៥កើត ដល់ថ្ងៃព្រហស្បត៍ ទី ១ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០១៩

**រៀបចំ និងសហការឧបត្ថម្ភដោយ៖**

## មាតិកា

អក្សរកាត់ ........ 3
1. សេចក្តីផ្តើម ........ 4
1.1 សន្ទរកថាស្វាគមន៍ និងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារអប់រំពិសេសកន្លងមក ........ 4
1.2 សន្ទរកថា ដោយ លោក សេង ហុង នាយកប្រតិបត្តិនៃអង្គការភាពជាដៃគូអង្គការអប់រំក្រៅរដ្ឋាភិបាល ........ 7
1.3 សន្ទរកថាដោយតំណាងរបស់អង្គការ UNICEF ........ 8
1.4 សន្ទរកថា ដោយ ឯកឧត្តម ជា ជាតិ ........ 10
2. ការធ្វើបទបង្ហាញអំពីបច្ចុប្បន្នភាពគោលនយោបាយអប់រំបរិយាបន្ន និងផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ........ 12
2.1. ការធ្វើបទបង្ហាញដោយ លោក ទឹម សាហែន អនុប្រធាន នាយកដ្ឋានអប់រំពិសេស ........ 12
2.2. បទបង្ហាញសង្ខេបអំពីការប្រព្រឹត្តិទៅរបស់វិទ្យាស្ថានជាតិអប់រំពិសេស ដោយលោក វន វី នាយករងវិទ្យាស្ថានជាតិអប់រំពិសេស ........ 16
2.3. ការបញ្ចាំងវីឌីអូ និងការណែនាំអំពីកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង ........ 17
2.4. ការបង្ហាញវីឌីអូអំពីសកម្មភាពជាក់ស្តែងដែលអង្គការក្រៅរដ្ឋាភិបាលបានអនុវត្តកន្លងមក ........ 18
2.5. បទបង្ហាញស្តីពីការចែករំលែកបទពិសោធន៍អំពីការអនុវត្តការអប់រំបរិយាបន្ននៅថ្នាក់ខេត្ត និងស្រុក ........ 18
2.6. បទបង្ហាញស្តីពីការចែករំលែកបទពិសោធន៍អំពីការអនុវត្តការអប់រំបរិយាបន្ននៅថ្នាក់សាលារៀន 20
2.7. បទបង្ហាញអំពីវឌ្ឍនភាពនៃសាលាបឋមសិក្សាទួលគោក ........ 22
2.8. បទបង្ហាញចែករំលែកបទពិសោធន៍អំពីការបង្រៀនកុមារមានពិការភាពផ្នែកសតិបញ្ញា ........ 23
2.9. បទបង្ហាញអំពីប្រកាសលេខ ១៦៧៧ ........ 24
2.10. បទបង្ហាញស្តីពីបរិយាកាសសាលារៀនបរិយាបន្ន ........ 25
3. កិច្ចពិភាក្សាតុមូលស្តីពីការបង្កើនការវិនិយោគលើការកសាងសមត្ថភាពគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ........ 26
4. កិច្ចពិភាក្សាជាក្រុម ........ 31

## អក្សរកាត់

| | | |
|---|---|---|
| AAR Japan | Association for Aid and Relief, Japan | សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន |
| CDPO | Cambodian Disabled People's Organization | អង្គការជនពិការកម្ពុជា |
| CRS | Catholic Relief Services | អង្គការស៊ីអារអែស |
| CSO | Civil Society Organization | អង្គការសង្គមស៊ីវិល |
| DAC | Disability Action Council | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DOE | District Office of Education | ការិយាល័យអប់រំស្រុក |
| EMIS | Education Management Information System | នាយកដ្ឋានប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំ |
| IE | Inclusive Education | ការអប់រំបរិយាបន្ន |
| KPF | Komar Pikar Foundation | អង្គការមូលនិធិកុមារពិការ |
| MoEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហរញ្ញវត្ថុ |
| MoEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoLVT | Ministry of Labor and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| NEP | NGO Education Partnership | ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NFIE | National Forum on Inclusive Education | វេទិកាជាតិស្តីពីការអប់រំបរិយាបន្ន |
| NGO | Non-governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NISE | National Institute of Special Education | វិទ្យាស្ថានជាតិអប់រំពិសេស |
| POE | Provincial Office of Education | មន្ទីរអប់រំ យុវជន និងកីឡា |
| RSO | Rabbit School Organization | អង្គការសាលារៀនទន្សាយ |
| SED | Special Education Department | នាយកដ្ឋានអប់រំពិសេស |
| SWD | Students with Disabilities | សិស្សមានពិការភាព |
| TTD | Teacher Training Department | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍន៍អន្តរជាតិ |
| WGED | Working Group on Education and Disabilities | ក្រុមការងារអប់រំ និងពិការភាព |

# 1. សេចក្តីផ្តើម

វេទិកាថ្នាក់ជាតិលើកទី ៨ ស្តីពីការអប់រំបរិយាបន្ន ក្រោមប្រធានបទ "បង្កើនការវិនិយោគលើការកសាងសមត្ថភាពគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនអំពីការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព" ត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០១៩ នៅអគាររដ្ឋបាល (ជាន់ទី១) នៃក្រសួងអប់រំ យុវជន និងកីឡា ក្រោមអធិបតីភាពរបស់ឯកឧត្តម ជា ជាតិ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកុមារ តំណាងដ៏ខ្ពង់ខ្ពស់បណ្ឌិតសភាចារ្យរដ្ឋមន្ត្រី លោក ថោង វិទ្ធិ ប្រធាននាយកដ្ឋានអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា លោកស្រី នាង ផល្លា នាយការវិទ្យាស្ថានជាតិអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា លោកស្រី Natascha Paddison ប្រធានអង្គការយូនីសេហ្វប្រចាំនៅប្រទេសកម្ពុជា ដោយមានការចូលរួមពីតំណាងអង្គការដៃគូ និងតំណាងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត។ វេទិកានេះត្រូវបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការសហការឧបត្ថម្ភពី ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) អង្គការយូនីសេហ្វ (UNICEF) សហភាពអឺរ៉ុប (EU) ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) អង្គការជនពិការកម្ពុជា។

របៀបវារៈរបស់វេទិកានេះរួមមាន៖ (១) សន្ទរកថាស្វាគមន៍ និងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារអប់រំពិសេស កន្លងមក (២) សន្ទរកថារបស់លោក សេង ហុង នាយកប្រតិបត្តិនៃអង្គការភាពជាដៃគូអង្គការអប់រំក្រៅរដ្ឋាភិបាល (៣) សន្ទរកថាដោយតំណាងរបស់អង្គការ UNICEF (៤) សន្ទរកថាដោយឯកឧត្តម ជា ជាតិ (៥) បទបង្ហាញអំពីបច្ចុប្បន្នភាពនៃគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងផែនការសកម្មភាពនៃការអប់រំបរិយាបន្ន (៦) បទបង្ហាញអំពីការចែករំលែកបទពិសោធន៍ពីអ្នកដែលពាក់ព័ន្ធ (៧) កិច្ចពិភាក្សាតុមូល និង (៨) កិច្ចពិភាក្សាជាក្រុម។

## 1.1 សន្ទរកថាស្វាគមន៍ និងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារអប់រំពិសេសកន្លងមក

ដើម្បីធ្វើឲ្យការងារបង្រៀនមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយដៃគូអភិវឌ្ឍ បានបង្កើត និងអនុវត្តការអប់រំបរិយាបន្នសម្រាប់ការសិក្សាពេញមួយជីវិត ដើម្បីអភិវឌ្ឍកាយសម្បទា បំណិនសម្បទា ចរិយាសម្បទា ឲ្យក្លាយទៅជាពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នាប្រកបដោយសុខដុមរមនានៅក្នុងសង្គម ដោយមានគោលបំណងឆ្លើយតបទៅនឹងគោល-នយោបាយ និងគោលដៅអភិវឌ្ឍប្រកបដោយចិរភាពទីបួន។

នៅក្នុងការអនុវត្តកន្លងមក យើងបានមើលឃើញថា សិស្សពិការគ្រប់ប្រភេទនៅគ្រប់ភូមិសិក្សាមានចំនួនសរុប ៦៤.៧០០ នាក់ ស្រី ២០.០២៩ នាក់ បុគ្គលិកនៅនាយកដ្ឋានអប់រំពិសេសមានចំនួនសរុប ២៨ នាក់ ស្រី ៩ នាក់ មន្ត្រីជាប់កិច្ចសន្យាមានចំនួន ៤ នាក់ បុគ្គលិកនៅវិទ្យាស្ថានជាតិអប់រំពិសេស មានចំនួនសរុប ៣៩ នាក់ ស្រី ៧ នាក់ បុគ្គលិកនៅវិទ្យាល័យអប់រំពិសេសទាំងប្រាំមានចំនួនសរុប ១៥៩ នាក់ ស្រី ៧៤ នាក់ ស្ថិតិសិស្សពិការភ្នែក និងគថ្លង់ នៅវិទ្យាល័យអប់រំពិសេសទាំងប្រាំ សម្រាប់ឆ្នាំសិក្សា ២០១៨-២០១៩ មានចំនួនសរុប ៧០២ នាក់ ស្រី ២២ នាក់ សិស្សពិការភ្នែក និងគថ្លង់ដែល

បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួនសរុប ១៨ នាក់ ស្រី ៩ នាក់ ស្មើនឹង ១០០% នៅឆ្នាំសិក្សា ២០១៨-២០១៩ សិស្សពិការភ្នែក និងគថ្លង់ នៅវិទ្យាល័យអប់រំពិសេសទាំងប្រាំចំនួន ៩ នាក់ ស្រី ២ នាក់ បានចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា។

ជាមួយគ្នានេះផងដែរ នាយកដ្ឋានអប់រំពិសេសបានដាក់ចេញនូវគោលនយោបាយស្តីពីការអប់រំបរិយាបន្ន នៅខែមិថុនា ឆ្នាំ២០១៨ បានអនុវត្តផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ឆ្នាំ២០១៩-២០២៣ នៅខែមេសា ឆ្នាំ២០១៩ បានប្រជុំពិភាក្សាលើសំណើសុំថវិកាលើកទឹកចិត្តដល់គ្រូបង្រៀនកុមារពិការ ដោយមានការចូលរួមពីក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ បានធ្វើសំណើសុំថវិកាចំនួន ៨០០.០០០ រៀលក្នុងមួយខែ ចាប់ពីខែមករា ឆ្នាំ២០១៩ រហូតដល់ខែធ្នូ ឆ្នាំ២០១៩ ជាប្រាក់បៀវត្សរ៍បន្ថែមសម្រាប់មន្ត្រីក្របខណ្ឌចំនួន ១៦៩ នាក់ ដែលបម្រើការនៅវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេសទាំងប្រាំ បានធ្វើសំណើសុំថវិកា ចំនួន ៨០០.០០០ រៀលក្នុងមួយខែ ចាប់ពីខែមករា ឆ្នាំ២០១៩ រហូតដល់ខែធ្នូ ឆ្នាំ២០១៩ សម្រាប់មន្ត្រីជាប់កិច្ចសន្យាចំនួន ៥ នាក់ ដែលបម្រើការងារនៅវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេសទាំងប្រាំ ដោយមានការឯកភាពពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន បានរៀបចំថវិកាអាហារូបករណ៍នៅវិទ្យាល័យអប់រំពិសេសទាំងប្រាំ ដែលមានសិស្សចំនួន ៧០២ នាក់ ក្នុងសិស្សម្នាក់ៗ ទទួលបានថវិកាចំនួន ២០០.០០០ រៀលក្នុងមួយខែ បានបង្កើតឯកសារកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារពិការ បានរៀបចំឯកសារជំនួយសម្រាប់អនុវត្តការកំណត់អត្តសញ្ញាណសេវាបញ្ជូនកុមារពិការ បានបង្កើតសេចក្តីណែនាំអំពីប្រព័ន្ធកំណត់អត្តសញ្ញាណសេវាបញ្ជូនកុមារពិការ បានរៀបចំប្រកាសលេខ ១៦៨៧ អយក. ប្រក. ស្តីពីការគ្រប់គ្រង និងការអនុវត្តកម្មវិធីអប់រំពិសេស នៅវិទ្យាស្ថានអប់រំសាធារណៈ និងរៀបចំថ្នាក់សមាហរណកម្មសម្រាប់សិស្សគថ្លង់ ពិការភ្នែក និងពិការសតិបញ្ញា។

ពាក់ព័ន្ធនឹងផ្នែកកិច្ចការបុគ្គលិក នាយកដ្ឋានអប់រំពិសេសបានបញ្ចូលគ្រូបង្រៀនកុមារពិការភ្នែក និងគថ្លង់ នៃអង្គការគ្រួសារថ្មី ចំនួន ៤៧ នាក់ ស្រី ២២ នាក់ ទៅក្នុងក្របខណ្ឌរដ្ឋ ស្របតាមប្រកាសលេខ ១៣០៦ អយក.ប្រក. ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ និងបានបញ្ចូលគ្រូបង្រៀនកុមារពិការភ្នែក និងគថ្លង់ នៅវិទ្យាល័យអប់រំពិសេសទាំងប្រាំ ចំនួន ២១ នាក់ ស្រី ៧ នាក់ ទៅក្នុងក្របខណ្ឌរដ្ឋ ស្របតាមប្រកាសលេខ ១៨៤២ អយក.ប្រក. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ នាយកដ្ឋានក៏បានរៀបចំតែងតាំងថ្នាក់ដឹកនាំនៃវិទ្យាស្ថានជាតិអប់រំពិសេស ការិយាល័យ ដេប៉ាតឺម៉ង់ និងបានតែងតាំងនាយករង នាយិការងនៃវិទ្យាល័យអប់រំពិសេសទាំងប្រាំ។

ពាក់ព័ន្ធនឹងការកសាងសមត្ថភាព នាយកដ្ឋានអប់រំពិសេសបានធ្វើវិក្រឹត្យការគ្រូបង្រៀនស្តីពីវិធី-សាស្ត្របង្រៀនសិស្សពិការភ្នែក និងគថ្លង់ ចំនួន ១២៥ នាក់ ស្រី ៧៦ នាក់ ក្នុងរយៈពេលប្រាំសប្តាហ៍ នៅក្នុងឆ្នាំ២០១៨ បានជ្រើសរើសគ្រូបង្រៀនអប់រំពិសេសដែលមានក្របខណ្ឌចំនួន ២០ នាក់ ស្រី ១៧ នាក់ សម្រាប់ធ្វើការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំពិសេស នៅក្នុងឆ្នាំ២០១៩ បានបំប៉នសមត្ថភាពគ្រូបង្គោលថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត និងថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត

នៅក្នុងក្របខណ្ឌស្តីពីការអប់រំបរិយាបន្នសម្រាប់បឋមសិក្សា ចំនួន ៧ រាជធានី-ខេត្ត ដោយប្រើប្រាស់ថវិការបស់ដៃគូអង្គការយូនីសេហ្វ។

ដើម្បីឲ្យការអប់រំសម្រាប់កុមារពិការប្រព្រឹត្តិទៅដោយជោគជ័យ ដោយមោទនភាព និងមានភាពរលូន យើងមានយន្តការការងារ និងរចនាសម្ព័ន្ធគ្រប់គ្រងតាមឋានានុក្រម ដែលបានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រុមការងារសកម្មភាពកុមារពិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង-ស្រុក-ខណ្ឌ និងក្រុមសកម្មភាពកុមារពិការថ្នាក់សាលារៀន។ យើងមានគោលនយោបាយស្តីពីការអប់រំបរិយាប័ន្ន និងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៩-២០២៣ នៅក្នុងការចង្អុលបង្ហាញទិសដៅច្បាស់លាស់ ដើម្បីជួយដល់អ្នកពាក់ព័ន្ធសម្រាប់ការងារកំណែទម្រង់នៅក្នុងប្រព័ន្ធ ក៏ដូចជា ផែនទីចង្អុលផ្លូវក្នុងការអនុវត្តគម្រោង។ យើងទទួលបានការឧបត្ថម្ភគាំទ្រពីអង្គការជាតិ និងអន្តរជាតិមួយចំនួន ដូចជា អង្គការយូនីសេហ្វ អង្គការ AAR ជប៉ុន អង្គការ CRS និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត។ យើងទទួលបានការជម្រុញ និងលើកទឹកចិត្ត ពីសំណាក់មាតាបិតាសិស្ស ការគាំទ្រពីសហគមន៍បានយ៉ាងល្អ យើងមានឯកសារបណ្តុះបណ្តាលនាយកលោកគ្រូ-អ្នកគ្រូ ស្តីពីការអប់រំបរិយាបន្ន យើងមានធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្តសម្រាប់ការអនុវត្តកម្មវិធី ជាពិសេស យើងមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ដែលមានការយល់ដឹងអំពីពិការភាព និងយកចិត្តទុកដាក់ចំពោះសិស្សដែលមានពិការភាព។ នាយកដ្ឋានអប់រំពិសេសបានដើរតួយ៉ាងសំខាន់នៅក្នុងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ។

ទោះបីជាមានការឧបត្ថម្ភគាំទ្រយ៉ាងណាក្តី យើងក៏នៅតែជួបប្រទះនឹងការលំបាកមួយចំនួន ដូចជា ថវិកាពុំទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង កុមារពិការធ្ងន់ធ្ងរនៅក្រៅសាលាមិនទាន់ទទួលបានសេវាព្យាបាល និងស្តារលទ្ធភាព កង្វះគ្រូដែលមានជំនាញអប់រំពិសេសសម្រាប់បង្រៀនកុមារពិការនៅតាមគ្រឹះស្ថានសាធារណៈ កង្វះអគារសម្រាប់សិស្សពិការភ្នែក និងគថ្លង់ ស្នាក់នៅ នៅក្នុងវិទ្យាល័យទាំងប្រាំ ធនធានមនុស្សពុំទាន់ឆ្លើយតបទៅនឹងតម្រូវការ និងពុំទាន់មានបទពិសោធន៍តាមប្រភេទពិការផ្សេងៗ ភាពក្រីក្ររបស់គ្រួសារកុមារពិការរាំងស្ទះដល់ការបញ្ជូនកូនចៅ និងកុមារជួបការលំបាកផ្សេងទៀតឲ្យមករៀនឲ្យបានគ្រប់ៗគ្នា ការផ្សព្វផ្សាយ និងការយល់ដឹងអំពីពិការភាពរបស់សហគមន៍ពុំទាន់មានភាពទូលំទូលាយនៅឡើយ កិច្ចសហប្រតិបត្តិការរវាងអង្គការដៃគូអភិវឌ្ឍ និងក្រសួងអប់រំ យុវជន និងកីឡា នៅមានកម្រិត ការរៀបចំថ្នាក់សមាហរណកម្ម គថ្លង់ ពិការភ្នែក និងសតិបញ្ញា មិនទាន់បានទូលំទូលាយនៅទូទាំងប្រទេស និងការផ្តល់សេវាស្តារលទ្ធភាពពលកម្មពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារដែលមានពិការភាព។

ចំពោះផែនការបន្ត នាយកដ្ឋានអប់រំពិសេសមានផែនការរៀបចំកញ្ចប់ថវិកាសម្រាប់សម្ភារៈរៀន និងបង្រៀន ការហូបចុកស្នាក់នៅ សោហ៊ុយធ្វើដំណើរ ដំណើរការរបស់សាលារៀន និងវិទ្យាល័យអប់រំពិសេសទាំងប្រាំ សម្រាប់ឆមាសបន្តបន្ទាប់ទៀត នៅក្នុងឆ្នាំ២០២០ និងរៀបចំកញ្ចប់ថវិកាសម្រាប់ដំណើរការរៀន និងបង្រៀននៅវិទ្យាល័យអប់រំពិសេសទាំងប្រាំ និងការផ្ទេរទៅឲ្យក្រសួងអប់រំ យុវជន និងកីឡា

នាពេលខាងមុខ។ យើងក៏មានផែនការរៀបចំគ្រូជំនាញផ្នែកអប់រំពិសេស គឺការបង្រៀនកុមារដែលមានពិការភាព នៅគ្រប់ភូមិសិក្សាសម្រាប់វិទ្យាល័យអប់រំពិសេសទាំងប្រាំ បន្តបញ្ចូលប្រាក់ឧបត្ថម្ភភារកិច្ចពិសេសចំនួន ៨០០.០០០ រៀល ទៅក្នុងអនុក្រឹត្យស្តីពីកំណែទម្រង់ប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល និងរៀបចំផែនការថវិកាសម្រាប់ជួសជុលអគារសិក្សា ទិញសម្ភារៈការិយាល័យនៅវិទ្យាល័យអប់រំពិសេសទាំងប្រាំ ជាថវិកាដំណើរការ ចំនួន ៦០ លានរៀលក្នុងមួយវិទ្យាល័យ។ យើងនឹងអនុវត្តផែនការតាមគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងផែនការសកម្មភាព អភិវឌ្ឍសមត្ថភាពមន្ត្រីថ្នាក់ជាតិ និងថ្នាក់ខេត្តទៅលើការងារអប់រំបរិយាបន្ន បន្តពង្រឹង និងពង្រីកការអនុវត្តកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារពិការឲ្យបានទូលំទូលាយនៅទូទាំងប្រទេស ធ្វើការពិនិត្យតាមដានទៅលើស្រុក-ខេត្តគោលដៅ និងដែលកំពុងអនុវត្តកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារដែលមានពិការភាព បន្តស្រង់ស្ថិតិកុមារពិការឲ្យបានច្បាស់លាស់ និងនៅគ្រប់រាជធានី-ខេត្ត និងបន្តធ្វើការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ដើម្បីធានាបាននូវនិរន្តរភាព និងគុណភាពនៃការអប់រំ។

ទន្ទឹមនឹងនេះ យើងក៏មានសំណូមពរមួយចំនួនផងដែរ ដូចជា ស្នើសុំថវិកាភាគីបន្ថែមសម្រាប់វគ្គបំប៉នសមត្ថភាព និងកម្រិតមូលដ្ឋានស្រុក-ខណ្ឌ ស្នើសុំដៃគូអភិវឌ្ឍន៍ឲ្យជួយឧបត្ថម្ភ និងគាំទ្រសកម្មភាព និងផែនការដែលក្រសួងបានដាក់ចេញ ស្នើសុំគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ដែលអនុវត្តកម្មវិធីអប់រំកុមារពិការជួយជាថវិកាសម្រាប់ការបំប៉នសមត្ថភាពគ្រូបង្រៀននៅតាមក្រុង-ស្រុក-ខណ្ឌ ដែលពុំបានទៅដល់ បង្កើនការផ្សព្វផ្សាយដល់សហគមន៍ និងអាណាព្យាបាលកុមារពិការ ព្រមទាំងការផ្តល់ឧបករណ៍ជំនួយ។

ជាចុងបញ្ចប់ ការអប់រំបរិយាបន្នសម្រាប់កុមារពិការមានការរីកចម្រើនជាបន្តបន្ទាប់ ដោយមានកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់ និងមានការគាំទ្រថវិកាពីអង្គការជាតិ និងអន្តរជាតិ។ ចាប់ពីពេលនេះតទៅ កុមារដែលមានការលំបាក ជាពិសេសកុមារពិការ នឹងបានទទួលការអប់រំគ្រប់ៗគ្នា និងទទួលបានការអប់រំប្រកបដោយសមធម៌ គុណភាព និងប្រសិទ្ធភាពខ្ពស់។

## 1.2 សន្ទរកថា ដោយ លោក សេង ហុង នាយកប្រតិបត្តិនៃអង្គការភាពជាដៃគូអង្គការអប់រំក្រៅរដ្ឋាភិបាល

ជាបឋម លោក សេង ហុង បានចូលរួមអបអរសាទរដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ជាពិសេសក្រសួងអប់រំ ដែលបានធ្វើកិច្ចសម្របសម្រួលកន្លងមក និងបានដាក់ចេញនូវទិសដៅសំខាន់ៗសម្រាប់ឆ្នាំ ២០២០-២០៣០ ដែលមានចែងនៅក្នុងគោលដៅទីបួននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព និងបានរំលេចឡើងនៅក្នុងផែនការសកម្មភាព ឆ្នាំ២០១៩-២០២៣ ព្រមទាំងគោលនយោបាយ និងផែនការសកម្មភាពសំខាន់ៗផ្សេងទៀតដែលបានបញ្ជាក់យ៉ាងច្បាស់លាស់អំពីនិន្នាការនៃកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ធ្វើយ៉ាងណាឲ្យពលរដ្ឋទាំងអស់ទទួលបានសេវាអប់រំប្រកបដោយគុណភាព ដូចជាគំនិត និងទិសដៅថ្មីៗដែលទាក់ទងនឹងការសិក្សាពេញមួយជីវិត ជាដើម។ ទន្ទឹមនឹងនេះដែរ ក្នុងនាមជាអង្គការសង្គមស៊ីវិល NEP បានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងកិច្ចផ្តួចផ្តើមទាំងឡាយ នៅក្នុងក្របខណ្ឌគោលនយោបាយ និងគម្រោងនានា ដែលបានអនុវត្ត និងរៀបចំកន្លងមក។ NEP បានធ្វើកិច្ចសម្របសម្រួលបង្កើតក្រុមការងារមួយដែលមានឈ្មោះថា "ក្រុមការងារអប់រំ និងពិការភាព" ដែលមានសហការីមកពីជាង

៣០ អង្គការ ដែលនៅក្នុងការរៀបចំឡើងនូវវេទិកានេះ ដើម្បីជាការគាំទ្រដល់នាយកដ្ឋានអប់រំបរិយាបន្ននៃក្រសួងអប់រំ ក្រុមការងារសង្គមស៊ីវិលនេះបានចូលរួមចំណែកនៅក្នុងការពិភាក្សា និងបង្កើតឡើងនូវនិន្នាការនៃវេទិកានេះផងដែរ។ NEP ក៏បានចូលរួមចំណែកជាលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុនៅក្នុងកិច្ចការសម្របសម្រួល ធ្វើយ៉ាងណាឲ្យវេទិកានេះអាចដំណើរការបាន។ ទន្ទឹមនឹងនោះដែរ នៅក្នុងលំហរនៃអង្គការសង្គមស៊ីវិល និងក្រោមកិច្ចសម្របសម្រួលរបស់ក្រុមការងារអនុវិស័យអប់រំបរិយាប័ន្ន ក្រុមការងារនេះក៏បានរៀបចំជាលំដាប់លំដោយនូវកិច្ចប្រជុំសំខាន់ៗនៅក្នុងក្រុមដើម្បីពិនិត្យមើលថាតើកិច្ចប្រឹងប្រែងរបស់ក្រុមការងារអាចចូលរួមយ៉ាងដូចម្តេចបានបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាឲ្យកិច្ចសម្របសម្រួលរាល់គោលនយោបាយ និងកម្មវិធីសំខាន់ៗរបស់រដ្ឋាភិបាល ទាក់ទងនឹងទិសដៅនៃការអប់រំដើម្បីទាំងអស់គ្នានេះ មានប្រសិទ្ធភាពកាន់តែខ្ពស់។ ទន្ទឹងនឹងនោះ ក្រុមការងាររបស់ NEP ក៏បានធ្វើកិច្ចពិភាក្សាយ៉ាងស៊ីជម្រៅថាតើ នៅក្នុងទិសដៅទៅមុខទៀត ដែលជាផែនទីចង្អុលផ្លូវរបស់អង្គការសង្គមស៊ីវិល គួរតែរៀបចំកែសម្រួលខ្លួនយ៉ាងដូចម្តេចដើម្បីធ្វើឲ្យធាតុចូលពីសង្គមស៊ីវិលកាន់តែមានភាពផ្តួចផ្តើម និងផ្តល់អត្ថប្រយោជន៍ខ្ពស់សម្រាប់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។ យ៉ាងណាក៏ដោយ យើងសង្កេតឃើញថាកិច្ចប្រឹងប្រែងទាំងអស់បានសម្តែងឡើងព្រមៗគ្នា ដែលរួមមាន កិច្ចខិតខំប្រឹងប្រែងពីអ្នកពាក់ព័ន្ធនៃស្ថាប័នសាធារណៈ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ផងដែរ។ យើងបានសង្កេតឃើញមានកិច្ចអន្តរាគមន៍ជាច្រើន ទាក់ទងនឹងគោលនយោបាយ និងសកម្មភាពមួយចំនួន ដើម្បីធ្វើកិច្ចការអប់រំសម្រាប់ទាំងអស់គ្នានេះឲ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសកិច្ចការងារទាក់ទងទៅនឹងការអប់រំបរិយាបន្ន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឲ្យកិច្ចការងារនេះកាន់តែមានឥទ្ធិពល និងមានប្រសិទ្ធភាពខ្ពស់ យើងប្រហែលជាត្រូវដាក់អន្តរាគមន៍មួយចំនួនបន្ថែមទៀត ដើម្បីជុំរិញការផ្តួចផ្តើមត្រៀម និងបង្ការ ដូច្នេះប្រហែលជាទាមទារឲ្យមានការចូលរួមបន្ថែមពីសាលារៀន មណ្ឌលអប់រំសុខភាព ឬក្រសួងសុខាភិបាលនៅកម្រិតណាមួយ ជាងនេះទៅទៀត ដូចជាប្រធានបទនៅថ្ងៃនេះ លោកគ្រូ អ្នកគ្រូនៅតាមសាលាសំខាន់ៗ រួមទាំងពីកុមារតូចរហូតទៅដល់វិទ្យាល័យ គឺមានសមត្ថភាពសមស្របមួយដែលអាចធ្វើការវាយតម្លៃជាមុន និងអាចជួយសម្របសម្រួលធ្វើយ៉ាងណាឲ្យអន្តរាគមន៍នៃបរិយាបន្ននេះអាចមានភាពសកល និងទូលំទូលាយនៅគ្រប់សាលារៀន។

ជាទីបញ្ចប់ លោក សេង ហុង បានចូលរួមអបអរសាទរចំពោះតួលេខមួយចំនួនដែលបានលើកឡើងដោយលោកប្រធាននាយកដ្ឋានអប់រំពិសេស អំពីតួលេខនៃជនពិការមានចំនួនច្រើន ដែលលោកគិតថា ប្រសិនបើយើងអាចពង្រីកចំនួននេះបន្ថែមទៀតបាន និងប្រសិនបើពួកគេទទួលបានការអប់រំដែលមានគុណភាពខ្ពស់ ដោយមានការសម្របសម្រួលបន្ថែមពីគ្រប់ភាគីបន្ថែមទៀត លោកជឿថា ដំណើរការនៅក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជានឹងមានការកើនឡើង។

## 1.3 សន្ទរកថាដោយតំណាងរបស់អង្គការ UNICEF

ជាកិច្ចចាប់ផ្តើម លោកស្រីបានថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល និងថ្នាក់ដឹកនាំទាំងឡាយ ដែលមកជួបជុំគ្នានៅក្នុងកិច្ចសំណេះសំណាល

ប្រចាំឆ្នាំស្តីពីការអប់រំបរិយាបន្នដ៏សំខាន់នេះ។ លោកស្រីក៏បានលើកឡើងផងដែរថា នៅក្នុងឆ្នាំនេះ យើងអាចមើលឃើញវឌ្ឍនភាពឥតឈប់ឈរនៃការអប់រំបរិយាបន្នសម្រាប់កុមារដែលមានពិការភាពតាមរយៈការបង្កើនការវិនិយោគលើការកសាងសមត្ថភាពរបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។ នេះគឺជាសកម្មភាពដ៏សំខាន់មួយសម្រាប់យើងទាំងអស់គ្នានៅក្នុងការគាំទ្រដល់ការផ្តល់ការអប់រំបរិយាបន្ន និងសេវានានាដល់កុមារមានពិការភាពនៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក លោកស្រីក៏បានទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា និងសមិទ្ធផលនានារបស់ក្រសួងអប់រំ យុវជន និងកីឡានៅក្នុងការបង្កើនការទទួលបានការអប់រំសម្រាប់កុមារមានពិការភាព។ នាពេលថ្មីៗនេះ លោកស្រីទើបតែទៅពិនិត្យមើលការគ្រប់គ្រង និងប្រតិបត្តិការរបស់វិទ្យាអប់រំពិសេសទាំងប្រាំនៅក្នុងប្រទេសកម្ពុជា ដែលកាលពីមុនបានធ្វើប្រតិបត្តិការដោយអង្គការមិនមែនរដ្ឋាភិបាល គ្រួសារថ្មី ដែលលោកស្រីបានមើលឃើញការដំណើរការនៃសាលារៀនទាំងនេះ និងការកសាងសមត្ថភាពរបស់គ្រូបង្រៀននាពេលអនាគត។ ធ្វើដូច្នេះ នឹងមានគ្រូបង្រៀនកាន់តែច្រើនដែលមានជំនាញនៅក្នុងការផ្តល់ជំនួយដល់ការមើលឃើញ និងការស្តាប់ឮ នៅក្នុងវិស័យអប់រំពិសេស។ គោលវិធីរបស់យូនីសេហ្វមានសេចក្តីសោមនស្សរីករាយនៅក្នុងការគាំទ្រចំពោះការងារដ៏សំខាន់នេះ យើងនឹងរង់ចាំផ្តល់ការគាំទ្រដល់វិទ្យាស្ថានជាតិអប់រំពិសេស និងបេសកកម្មរបស់វិទ្យាស្ថាននេះជាបន្តបន្ទាប់ទៀត។ លើសពីនេះទៀត លោកស្រីក៏ទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងនៅក្នុងការអភិវឌ្ឍគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងឯកសារនានា ដែលបានបង្កើតផែនការច្បាស់លាស់មួយសម្រាប់ការងារដ៏អស្ចារ្យផងដែរ។ សមិទ្ធផលទាំងនេះសុទ្ធតែមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជនពិការនៅក្នុងប្រទេសកម្ពុជា ដែល ៩,៥% នៃប្រជាជនកម្ពុជា ធ្លាប់ឆ្លងកាត់ពិការភាពយ៉ាងតិចមួយទម្រង់ និងកុមារចំនួន ១៥% ត្រូវបានគេប៉ាន់ស្មានថា មានភាពទន់ខ្សោយផ្នែកណាមួយ នៅក្នុងឆ្នាំ២០០៩។ កុមារមានពិការភាពនៅក្នុងប្រទេសកម្ពុជាទំនងជាមិនបានចូលរៀន ច្រើនជាងកុមារធម្មតាពីរដង។ កុមារមានពិការភាពនៅក្នុងប្រទេសកម្ពុជា ភាគច្រើននៅតែបន្តស្ថិតនៅក្នុងវដ្តអាជីវកម្ម និងមានភាពខ្វះខាត។ នៅពេលនេះ ដូចដែលអ្នកទាំងអស់គ្នាក៏ប្រហែលជាឯកភាពដែរ ការដាក់បញ្ចូលការអប់រំបរិយាបន្នទៅក្នុងកិច្ចតែងការបង្រៀនគឺជាជំហានដ៏សំខាន់ និងចាំបាច់មួយ។ ប៉ុន្តែ ការងារមិនបញ្ចប់ត្រឹមនេះនេះទេ។ អាទិភាពដ៏សំខាន់មួយ គឺជាប្រព័ន្ធអប់រំបរិយាបន្ន និងប្រព័ន្ធអប់រំពិសេសដែលបំពេញមុខងារបានល្អ នៅក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងការអប់រំ ធ្វើដូច្នេះ ពួកគេនឹងអាចផ្តល់សេវាដែលមានគុណភាពកាន់តែល្អប្រសើរដល់កុមារមានពិការភាព។ នៅយូនីសេហ្វ យើងប្តេជ្ញាចិត្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង តាមរយៈនាយកដ្ឋានអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស ដើម្បីពង្រឹងចំណេះដឹង និងជំនាញរបស់អ្នកដែលមានចំណេះដឹងឲ្យកាន់តែស៊ីជម្រៅឡើង និងការដាក់បញ្ចូលទៅក្នុងការអប់រំពិសេស តាមរយៈការបណ្តុះបណ្តាលសេវារដ្ឋបាលចំនួនបី។ យើងនៅតែសង្ឃឹមថា ការរួមចំណែករបស់យូនីសេហ្វនៅក្នុងការកសាងសមត្ថភាពរបស់គ្រូបង្រៀនដែលមានវិជ្ជាជីវៈនៅក្នុងវិស័យនេះនឹងអាចធ្វើឲ្យកុមារមានពិការភាពមានមោទនភាពចំពោះសាលារៀន រហូតដល់ពួកគេប្រាកដថា យើងមិនទុកការអប់រំប្រៀនប្រដៅចោលនោះទេ។ ជាចុងបញ្ចប់ លោកស្រីបានលើកឡើងថា ការអប់រំបរិ

យាបន្នតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការដ៏ខ្លាំងក្លាមួយរវាងវិស័យនានា និងជាមួយអ្នកពាក់ព័ន្ធជាច្រើន ដើម្បីធានាថា តម្រូវការរបស់កុមារមានពិការភាពត្រូវបានបំពេញតាម។

### 1.4 សន្ទរកថា ដោយ ឯកឧត្តម ជា ជាតិ

ជាបឋម ឯកឧត្តម ជា ជាតិ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា តំណាងដ៏ខ្ពស់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី មានប្រសាសន៍ថា ឯកឧត្តមមានកិត្តិយសខ្លាំងណាស់ដែលបាន តំណាងឲ្យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មកចូលរួមនៅក្នុងវេទិកាថ្នាក់ ជាតិលើកទី៨ នេះ។ ឯកឧត្តមបានថ្លែងអំណរគុណដល់កុមារដែលមកពីសាលារៀនភ្នំពេញថ្មី និងអង្គការ Epic Art សម្រាប់ការរាំរបាំ និងការសម្តែង ដែលពួកគេគឺជាកុមារពិការ ប៉ុន្តែមានសមត្ថភាពសម្តែង សិល្បៈ។ ឯកឧត្តមបានថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍នានា ដូចជា អង្គការយូនីសេហ្វ និងអង្គការ AAR ជប៉ុន ជាដើម ដែលបានផ្តល់ការគាំទ្រជារៀងរហូតមក ហើយឯកឧត្តមក៏បានថ្លែងអំណរគុណដល់ វត្តមានរបស់គណៈអធិបតី និងអ្នកចូលរួមទាំងអស់គ្នា ដែលមានវត្តមាននៅក្នុងអង្គពិធីទាំងមូលផងដែរ ដែលវត្តមានរបស់អ្នកទាំងអស់គ្នា គឺជាការបង្ហាញអំពីការគាំទ្រយ៉ាងខ្លាំងក្លាដល់ការអប់រំបរិយាបន្ន។

ឆ្លៀតនៅក្នុងឱកាសនោះផងដែរ ឯកឧត្តមបានរំឭកឡើងវិញអំពីព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ មួយចំនួន ដែលរួមមាន កិច្ចប្រជុំរដ្ឋាភិបាលនៅបណ្តាប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក ដែលបានប្រារព្ធធ្វើឡើង នៅទីក្រុងអ៊ីនឈន់ សាធារណរដ្ឋកូរ៉េ ចាប់ពីថ្ងៃទី២៩ ខែតុលា រហូតដល់ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២។ កិច្ចប្រជុំនេះបានលើកឡើងអំពី "ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក" ដែលធ្វើការប្រជុំរៀងរាល់ ១០ ឆ្នាំម្តង និងបានដាក់ចេញនូវយុទ្ធសាស្ត្រដ៏ធំមួយ ហៅថា យុទ្ធសាស្ត្រអ៊ីនឈន់ ដែលផ្តោតលើការ ជួយដល់ជនពិការនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមានចំនួន ៦៥០ លាននាក់ (១៥%) នៅក្នុងចំណោម ប្រជាជនចំនួន ៤៥៦០ លាននាក់ នៅក្នុងទ្វីបអាស៊ី ដែល ៨០% នៃជនពិការទាំងនេះរស់នៅក្នុងប្រទេស កំពុងអភិវឌ្ឍន៍។ យុទ្ធសាស្ត្រនេះ បានលើកឡើងអំពីការធ្វើឲ្យសិទ្ធិរបស់ជនពិការក្លាយទៅជាការពិត។ យុទ្ធសាស្ត្រនេះមាន ១០ ចំណុច ក្នុងនោះចំណុចទីប្រាំនិយាយអំពីសិទ្ធិទទួលបានការអប់រំ ការប្រមូលកុមារឲ្យចូលរៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ ដែលមានទំនាក់ទំនងទៅនឹងការអប់រំបរិយាបន្ននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ដូច្នេះប្រទេសកម្ពុជាយើងក៏បានយកយុទ្ធសាស្ត្រនេះមកអនុវត្ត ស្របតាមការវាយតម្លៃរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីសេដ្ឋកិច្ច និងសង្គម (ESCAP) ដែលបានវាយតម្លៃថាកម្ពុជាគឺជាប្រទេសទីមួយនៅតំបន់អាស៊ីប៉ាស៊ីហ្វិកដែលបានធ្វើពិធីប្រកាសជាផ្លូវ ការអំពីការប្តេជ្ញា-ចិត្តអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ ទសវត្សរ៍ជនពិការ ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈន់ "ធ្វើឲ្យសិទ្ធិក្លាយទៅជាការពិត" នៅ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ក្រោមអធិបតីភាព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋ មន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា នៅវិមានសន្តិភាព។

ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមបានរំឭកអំពីស្នាដៃរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹង បញ្ហាជនពិការ ដែលរួមមាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានប្រកាស

អំពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក យុទ្ធសាស្ត្រអ៊ីនឈាន់ និងរាជរដ្ឋាភិបាលកម្ពុជាបានធ្វើសមាហរណកម្មវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេសចំនួនប្រាំ ឲ្យចូលមកក្រោមការគ្រប់គ្រងរបស់រដ្ឋ ដោយសម្តេចនាយករដ្ឋមន្ត្រីបានប្រកាសជាផ្លូវនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។ ទន្ទឹមនឹងនោះផងដែរ រដ្ឋាភិបាលក៏បានដាក់បញ្ចូលការអប់រំបរិយាបន្នទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបួន និងបានជម្រុញយ៉ាងខ្លាំងលើការអប់រំបរិយាបន្ននេះ។ ជាមួយគ្នានេះដែរ ក្រសួងអប់រំក៏បានបង្កើតផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ ដែលការលើកកម្ពស់ការអប់រំបរិយាបន្ន និងបានបង្កើតគោលនយោបាយជាតិស្តីពីការអប់រំបរិយាបន្ន។ ការអប់រំបរិយាបន្ន គឺជាការអប់រំដែលមិនចោលអ្នកណាម្នាក់ គឺជាការអប់រំដោយប្រមូលកុមារទាំងអស់នៅវ័យសិក្សាឲ្យមកទទួលការអប់រំ ដែលទាមទារឲ្យកុមារដែលមានពិការភាពគ្រប់ប្រភេទមកចូលរៀនជាមួយកុមារដែលគ្មានពិការភាព បង្កើតបានជាថ្នាក់អប់រំបរិយាបន្ន កុមារជនជាតិដើមដែលប្រើភាសារបស់ខ្លួនតាំងពីកំណើតក៏ត្រូវតែរៀនភាសាខ្មែរ ហើយកុមារដែលមានបញ្ញាខ្ពស់ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអប់រំពិសេសផងដែរ។ ដូច្នេះការអប់រំបរិយាបន្នទាមទារឲ្យប្រព័ន្ធអប់រំពង្រឹងសមត្ថភាពរបស់ខ្លួនឲ្យកាន់តែខ្លាំងក្លា គឺមិនត្រឹមតែបង្កើតវិធីសាស្ត្របង្រៀន និងសៀវភៅសិក្សាសម្រាប់សិស្សដែលមិនពិការប៉ុណ្ណោះទេ ក៏ប៉ុន្តែយើងក៏ត្រូវពង្រឹងសមត្ថភាពរបស់កុមារគថ្លង់ កុមារពិការភ្នែក កុមារជនជាតិដើម ឲ្យបានរៀននៅក្នុងថ្នាក់អប់រំបរិយាបន្នជាមួយគ្នាផងដែរ។ ប៉ុន្តែចំពោះកុមារដែលមានពិការភាពខ្លាំង ដែលមិនអាចរៀនជាមួយកុមារធម្មតាបាន យើងបានអនុញ្ញាតឲ្យពួកគេរៀនដាច់ដោយឡែក ដោយបានបង្កើតជាថ្នាក់សមាហរណកម្ម ដូច្នេះការអប់រំបរិយាបន្ន ពិតជាអនុវត្តសិទ្ធិមនុស្សបានយ៉ាងពេញលេញ។ ការអប់រំបរិយាបន្ន គឺជាការងារសំខាន់មួយដែលធ្វើឲ្យឪពុកម្តាយមានការពេញចិត្តនឹងបញ្ជូនកូនៗរបស់គាត់មកសាលារៀន ដើម្បីធ្វើឲ្យគាត់មានឱកាសទៅរកទទួលទានជំនួសឲ្យការចំណាយពេលវេលាជាច្រើននៅក្នុងការមើលថែទាំកូនៗ ដោយមិនអាចទៅរកទទួលទានអ្វីបាន។ ទោះបីជាកុមារមានបញ្ហាសតិបញ្ញារៀនមិនឡើងថ្នាក់ដូចកុមារដទៃទៀតក៏ដោយ ក៏យើងអាចបង្រៀនអំពីអាកប្បកិរិយា ការស្លៀកពាក់ និងការសម្រួលឥរិយាបថបានមួយចំនួនផងដែរ។ ជាឧទាហរណ៍ នៅសាលារៀនទន្សាយ បច្ចុប្បន្ន ឪពុកម្តាយបាននាំកូនៗរបស់ពួកគេមកចុះឈ្មោះចូលរៀនបានរហូតដល់ជាង ១៨០ នាក់ ដែលនៅពេលនេះបណ្តាលឲ្យមានបញ្ហាកង្វះខាតគ្រូបង្រៀន ប៉ុន្តែក្រសួងក៏បានរៀបចំដាក់ពាក្យស្នើសុំទៅកាន់ឯកឧត្តមរដ្ឋមន្ត្រីរួចរាល់ហើយ ដោយយើងកំពុងតែរង់ចាំការឯកភាពរបស់ឯកឧត្តមរដ្ឋមន្ត្រី។ ការអប់រំបរិយាបន្ននេះមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះការអប់រំបរិយាបន្នធ្វើឲ្យគុណភាពនៃការអប់រំមានភាពល្អប្រសើរឡើង និងឆ្លើយតបទៅនឹងបរិបទពិភពលោកដែលគេចង់បាន។ ហើយការអប់រំបរិយាបន្នក៏បានបង្កើនកិត្យានុភាពរបស់ប្រទេសកម្ពុជានៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកផងដែរ។

ជាមួយគ្នានោះផងដែរ ឯកឧត្តមបានលើកឡើងថា វេទិកាមានភាពខុសគ្នាពីសិក្ខាសាលា ដែលវេទិកានេះតម្រូវឲ្យមានការបញ្ចេញយោបល់ពីអ្នកចូលរួមគ្រប់រូប ទាក់ទងនឹងការអប់រំបរិយាបន្ន ដើម្បីធ្វើឲ្យការអប់រំបរិយាបន្ន មានសមធម៌ និងមានគុណភាព។ ឯកឧត្តមបានស្នើសុំឲ្យមានការបញ្ចេញយោបល់

យ៉ាងប្រាកដប្រជា ពីតំណាងអង្គការដៃគូ តំណាង NGO តំណាងនាយកដ្ឋានហិរញ្ញវត្ថុ តំណាងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត វិទ្យាស្ថានជាតិអប់រំពិសេស វិទ្យាល័យអប់រំពិសេស ដែលមានវត្តមាននៅក្នុងវេទិកានេះផងដែរ ដើម្បីធ្វើឲ្យការអប់រំបរិយាបន្នកាន់តែមានអត្ថន័យ និងកាន់តែទទួលបានភាពជោគជ័យបន្ថែមទៀត ស្របតាមទិសដៅរបស់រាជរដ្ឋាភិបាល និងទិសដៅរបស់ក្រសួង។ ឯកឧត្តមជឿជាក់ថា បន្ទាប់ពីបញ្ចប់វេទិកាថ្នាក់ជាតិលើកទី៨នេះហើយ យើងនឹងទទួលបានធាតុចូលល្អៗជាច្រើន ដើម្បីលើកកម្ពស់ការអប់រំបរិយាបន្ន។ ប្រសិនបើយើងមានការយល់ដឹងនៅកម្រិតដូចគ្នា យើងប្រើប្រាស់ភាសាតែមួយ យើងជ្រុំជ្រែងគ្នា យើងពិតជាទទួលបានជោគជ័យ។

ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមក៏បានថ្លែងអំណរគុណ និងកោតសរសើរចំពោះបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានធ្វើកំណែទម្រង់លើគ្រប់វិស័យ ជាពិសេសវិស័យអប់រំបរិយាបន្ន។ ឯកឧត្តម ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងក្នុងនាមឯកឧត្តមផ្ទាល់ សូមធ្វើការកោតសរសើរដោយស្មោះចំពោះក្រុមការងារ លោកគ្រូ អ្នកគ្រូ និងដៃគូដែលបានអនុវត្តការងារនេះឲ្យទទួលបានលទ្ធផលជាផ្លែផ្កា និងការថែរក្សាបាននូវនិរន្តរភាពក្នុងការអនុវត្តការងារអប់រំបរិយាបន្ន ជាពិសេសអស់លោក លោកស្រីដែលបានចូលរួមធ្វើសកម្មភាពនៅតាមមូលដ្ឋានរបស់ខ្លួន និងជួយប្រមូលកុមារនៅក្នុងវ័យសិក្សាឲ្យចូលរៀន ហើយក៏សូមកោតសរសើរចំពោះលោកគ្រូ អ្នកគ្រូ និងដៃគូអភិវឌ្ឍទាំងអស់ដែលមានមនសិកាខ្ពស់ ស្ម័គ្រចិត្តចូលរួម ទោះបីជាមានការលំបាកក៏ដោយ។ ការងារនេះពិតជាមានការលំបាកស្មុគស្មាញ ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការងារបច្ចេកទេសផងដែរ ដែលទាមទារឲ្យមន្ត្រីទទួលបន្ទុកការងារគ្រប់លំដាប់ថ្នាក់ គណៈកម្មការ លោកគ្រូ អ្នកគ្រូ ធ្វើពលិកម្មយ៉ាងពេញទំហឹងដើម្បីចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយអង្គការដៃគូនានាដើម្បីជួយកុមារពិការទាំងអស់ឲ្យទទួលបានការអប់រំពេញមួយជីវិត។ ឯកឧត្តមបានសម្តែងនូវក្តីសង្ឃឹមយ៉ាងមុតមាំថា វេទិកាថ្នាក់ជាតិនេះនឹងផ្តល់ជូនអ្នកចូលរួមគ្រប់រូបនូវខ្លឹមសារសំខាន់ៗដើម្បីយកទៅអនុវត្តឲ្យទទួលបាននូវលទ្ធផលល្អប្រសើរ។ ឯកឧត្តមបានសម្តែងនូវក្តីសង្ឃឹមយ៉ាងកក់ក្តៅចំពោះអង្គការដៃគូពាក់ព័ន្ធ ដែលបាន និងកំពុងជួយជាថវិកា និងបច្ចេកទេស នឹងបន្តជួយពង្រឹង និងពង្រីកការអប់រំបរិយាបន្នឲ្យទទួលបានលទ្ធផលល្អ។ ជាទីបញ្ចប់ ឯកឧត្តមបានប្រកាសបើកវេទិកាថ្នាក់ជាតិលើកទី៨ ជាផ្លូវការ។

## 2. ការធ្វើបទបង្ហាញអំពីបច្ចុប្បន្នភាពគោលនយោបាយអប់រំបរិយាបន្ន និងផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន

### 2.1. ការធ្វើបទបង្ហាញដោយ លោក ទឹម សាហែន អនុប្រធាន នាយកដ្ឋានអប់រំពិសេស

លោក ទឹម សាហែន បានបង្ហាញអំពីសាវតាររបស់នាយកដ្ឋានអប់រំពិសេស ដោយចាប់ផ្តើមពីការិយាល័យអប់រំពិសេស ដែលត្រូវបានបង្កើតឡើងនៅក្រោមនាយកដ្ឋានបឋមសិក្សា នៅក្នុងឆ្នាំ ២០០០។ ដោយឡែក នៅក្នុងឆ្នាំ២០១៦ ការិយាល័យអប់រំពិសេសនោះបានប្រែក្លាយមកជានាយកដ្ឋានអប់រំពិសេស ដោយមានលោក ថោង រិទ្ធី ជាប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន ចំនួន ៣ រូប ដែលក្នុងចំណោមនោះ អនុប្រធាននាយកដ្ឋាន ២ រូប បានចូលនិវត្តហើយ។ នាយកដ្ឋានមានការិយាល័យ

ចំនួនបួន គឺការិយាល័យរដ្ឋបាល ការិយាល័យអប់រំពិសេស ការិយាល័យផែនការ និងកិច្ចសហប្រតិបត្តិការ និងការិយាល័យអប់រំអ្នកបញ្ញាខ្ពស់។ លោក ទឹម សាហៃន បានបកស្រាយត្រួសៗអំពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន ដែលនៅក្នុងនោះ រួមមាន សេចក្តីផ្តើម ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្រ្ត (៩ យុទ្ធសាស្រ្ត) ផែនការសកម្មភាព ការត្រួតពិនិត្យ និងការវាយតម្លៃ និងសេចក្តីសន្និដ្ឋាន។

គោលនយោបាយនេះ មានចក្ខុវិស័យអភិវឌ្ឍជនដែលមានសេចក្តីត្រូវការពិសេសគ្រប់រូបឲ្យទទួលបានការអប់រំពេញមួយជីវិត ដែលប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌។

គោលនយោបាយនេះមានគោលបំណងបណ្តុះការអប់រំដល់ជនដែលមានសេចក្តីត្រូវការពិសេសឲ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ។ មានគោលដៅ ធានាឲ្យបាននូវការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការធ្វើអន្តរាគមន៍បានទាន់ពេលវេលា ការផ្តល់សេវាអប់រំដែលមានគុណភាព ប្រកបដោយបរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិត ការកសាងសមត្ថភាព និងលើកកម្ពស់ការអភិវឌ្ឍជំនាញដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន និងលើកកម្ពស់ការយល់ដឹង និងការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់។

គោលនយោបាយនេះមានយុទ្ធសាស្រ្តចំនួនប្រាំបួន ដែលរួមមាន ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ កិច្ចសហការអន្តរក្រសួងនៅក្នុងការកំណត់អត្តសញ្ញាណ ការអភិវឌ្ឍប្រព័ន្ធមូលដ្ឋានទិន្នន័យ និងព័ត៌មាន ផ្តល់ការអប់រំដែលមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌ ធានាឲ្យបាននូវឱកាសអប់រំប្រកបដោយគុណភាព សមភាព និងសមធម៌សម្រាប់សិស្សស្រីដែលមានសេចក្តីត្រូវការអប់រំពិសេស អភិវឌ្ឍគំនូសប្លង់តាមបរិបទក្នុងប្រទេស សម្រាប់ការសាងសង់អគារ និងអនាម័យស្អាត កសាងសមត្ថភាពគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន លើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការផ្សព្វផ្សាយទៅកាន់អ្នកពាក់ព័ន្ធ។

គោលនយោបាយនេះមានផែនការបង្កើតយន្តការ បង្កើតក្របខណ្ឌគតិយុត្តិ គាំទ្រហិរញ្ញវត្ថុ និងដំណើរការអនុវត្តគម្រោង។ រាល់ផែនការទាំងអស់ដែលបានដាក់ចេញមកតម្រូវឲ្យមានការត្រួតពិនិត្យឲ្យបានត្រឹមត្រូវ ដើម្បីទទួលបានលទ្ធផលមួយដែលអាចទទួលយកបាន។

គោលនយោបាយស្តីពីការអប់រំបរិយាបន្នត្រូវបានអនុម័តនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ និងបានធ្វើការផ្សព្វផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ នៅខេត្តកំពង់ចាម។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយស្តីពីការអប់រំបរិយាបន្ន នាយកដ្ឋានអប់រំពិសេសបានបង្កើតផែនការសកម្មភាពសម្រាប់គាំទ្រគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងដាក់ចេញនូវសកម្មភាពរយៈពេលវែង និងរយៈពេលមធ្យម សម្រាប់អនុវត្តរយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ២០១៩ រហូតដល់ ឆ្នាំ ២០២៣។ ក្នុងនោះដែរ ផែនការសកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២០ រួមមាន៖

- ធ្វើសុពលភាព និងផ្សព្វផ្សាយឯកសារ បទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការអប់រំបរិយាបន្ន និងអ្នកសិក្សាពូកែដែលមានទេពកោសល្យ និង/ឬមានបញ្ញាខ្ពស់
- កិច្ចប្រជុំរៀបចំផែនការសកម្មភាពជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងការអប់រំបរិយាបន្ន បញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង មន្ទីររាជធានី-ខេត្ត ការិយាល័យអប់រំ ក្រុង-ស្រុក-ខណ្ឌ និងសាលារៀន
- រៀបចំឧបករណ៍សម្រាប់កំណត់អត្តសញ្ញាណពិការភាព
- រៀបចំឧបករណ៍សម្រាប់ធ្វើលក្ខណៈវិនិច្ឆ័យអ្នកសិក្សាពូកែដែលមានទេពកោសល្យ និង/ឬមានបញ្ញាខ្ពស់
- បង្កើតឧបករណ៍ពិនិត្យតាមដានការសិក្សាស្តីពីតម្រូវការ និងបញ្ហាប្រឈមនៅក្នុងការសិក្សារបស់ជនដែលមានសេចក្តីត្រូវការពិសេស រៀងរាល់ពីរដងក្នុងមួយឆ្នាំ។
- ធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីសិទ្ធិទទួលបានសេវាអប់រំជនពិការដល់សហគមន៍ មាតាបិតា ដើម្បីប្រមូលកុមារមានពិការភាពឲ្យចុះឈ្មោះចូលរៀន
- ផ្តល់ការគាំទ្រដល់សិស្សដែលមានពិការភាពដើម្បីធានាថាអ្នកសិក្សាទាំងនោះទទួលបានការអប់រំប្រកបដោយសមធម៌ និងគុណភាព (កន្លែងស្នាក់នៅ ស្បៀងអាហារ និងមធ្យោបាយដឹកជញ្ជូន)
- កែសម្រួលកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលដៅជាអក្សរស្ទាប និងសៀវភៅភាសាសញ្ញាសម្រាប់បង្រៀនកុមារពិការភ្នែកនៅគ្រប់កម្រិតថ្នាក់ និងនិយាមសិស្ស គ្រូកំណត់តាមតម្រូវការជាក់ស្តែងរបស់សិស្ស
- បំប៉នគ្រូអំពីការប្រើប្រាស់កម្មវិធីសិក្សាតាមជំនាញ (ពិកាភ្នែក គ ថ្លង់ ពិការសតិបញ្ញា)
- ពង្រឹងថ្នាក់សមាហរណកម្មនៅគ្រប់ភូមិសិក្សា ដើម្បីផ្តល់ការអប់រំឲ្យបានសមស្របទៅនឹងអាយុរបស់ជនដែលមានសេចក្តីត្រូវការពិសេស
- ពង្រឹងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បន្ទប់ទឹកសម្រាប់ជនដែលមានសេចក្តីត្រូវការពិសេស
- បណ្តុះបណ្តាលគ្រូបង្រៀនចំនួន ២០ នាក់ សម្រាប់បង្រៀនជនដែលមានសេចក្តីត្រូវការពិសេសនៅក្នុងឆ្នាំ២០២០
- លើកទឹកចិត្តគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាល ឬបំប៉ន និងមានបទពិសោធន៍ផ្នែកអប់រំពិសេស ឲ្យទទួលបានវិញ្ញាបនបត្រ និងសញ្ញាបត្រផ្នែកអប់រំពិសេស
- អភិវឌ្ឍម៉ោងសម្រាប់កម្មវិធីបណ្តុះបណ្តាលរយៈពេលវែង និងវិក្រឹត្យការរយៈពេលខ្លី
- អនុវត្តសេចក្តីណែនាំស្តីពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធតាមកម្រិត ថ្នាក់ក្រសួង មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ និងសាលារៀន។

ទន្ទឹមនឹងនោះ នាយកដ្ឋានអប់រំពិសេសក៏ជួបប្រទះនឹងការលំបាកនានាផងដែរ ដែលរួមមានៈ

- ថវិកាកម្មវិធីពុំឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- កុមារពិការធ្ងន់ធ្ងរនៅក្រៅសាលារៀន មិនទាន់ទទួលបានសេវាអប់រំ ព្យាបាល និងស្តារលទ្ធភាព
- ខ្វះគ្រូជំនាញផ្នែកអប់រំពិសេសសម្រាប់បង្រៀនកុមារពិការ
- ខ្វះអគារសម្រាប់សិស្សពិការភ្នែក គ ថ្លង់ ស្នាក់នៅ
- ធនធានមនុស្សដែលយើងមាន ពុំទាន់មានបទពិសោធន៍តាមប្រភេទនៃពិការភាព
- ស្ថានភាពក្រីក្ររបស់គ្រួសារកុមារពិការរាំងស្ទះដល់ការបញ្ជូនកូនចៅពិការ និងកុមារជួបការលំបាកផ្សេងៗទៀតឲ្យមករៀនគ្រប់ៗគ្នា
- ការផ្សព្វផ្សាយ និងការយល់ដឹងអំពីពិការភាពរបស់សហគមន៍ពុំទាន់បានទូលំទូលាយនៅឡើយ
- កិច្ចសហការរវាង NGOs និងក្រសួងអប់រំ យុវជន និងកីឡា នៅមានកម្រិត
- ការរៀបចំថ្នាក់សមាហរណកម្មសម្រាប់សិស្ស គ ថ្លង់ ពិការភ្នែក និងពិការសតិបញ្ញា មិនទាន់បានទូលំទូលាយ
- ការផ្តល់សេវាស្តារលទ្ធភាពពលកម្មពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារមានពិការភាព។

បន្ទាប់មកទៀត លោក ទឹម សាហៃន បានបង្ហាញអំពីការផែនការបន្តដែលនាយកដ្ឋានបានដាក់ចេញ ដែលរួមមាន៖

- បន្តបញ្ចូលប្រាក់ឧបត្ថម្ភភារកិច្ចអប់រំពិសេសចំនួន ៨០ ម៉ឺនរៀល ទៅក្នុងអនុក្រឹត្យកំណែទម្រង់បៀវត្សរ៍របស់មន្ត្រីរាជការ
- រៀបចំផែនការថវិកាសម្រាប់ជួសជុលអគារសិក្សា និងទិញសម្ភារការិយាល័យនៅវិទ្យាល័យអប់រំពិសេសទាំងប្រាំ ចំនួន ៦០ លានរៀលក្នុងមួយវិទ្យាល័យ
- អនុវត្តផែនការ ស្របតាមគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងផែនការសកម្មភាព
- អភិវឌ្ឍសមត្ថភាពមន្ត្រីថ្នាក់ជាតិ និងថ្នាក់ខេត្តលើការងារអប់រំបរិយាបន្ន
- បន្តពង្រឹង និងពង្រីកការអនុវត្តកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព
- ធ្វើការពិនិត្យតាមដាននៅតាមគោលដៅដែលបាន និងកំពុងអនុវត្តកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព
- បន្តស្រង់ស្ថិតិកុមារឲ្យបានច្បាស់លាស់នៅគ្រប់រាជធានី-ខេត្ត
- បន្តធ្វើការទំនាក់ទំនងជាមួយអង្គការដៃគូ។

ឆ្លៀតក្នុងឱកាសនោះដែរ លោក ទឹម សាហៃន បានធ្វើការសំណូមពរមួយចំនួនដូចខាងក្រោម៖

- ស្នើសុំបង្កើតថវិកា PB ដើម្បីបើកវគ្គបំប៉នសមត្ថភាពគ្រូបង្រៀនបន្តទៀត នៅតាមមូលដ្ឋានក្រុង-ស្រុក-ខណ្ឌ
- ស្នើសុំគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ជួយឧបត្ថម្ភគាំទ្រសកម្មភាពលើផែនការដែលក្រសួងបានដាក់ចេញ

- ស្នើសុំគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ជួយអនុវត្តកម្មវិធីអប់រំកុមារពិការ ជួយផ្តល់ថវិកាសម្រាប់ការបំប៉នសមត្ថភាពគ្រូបង្រៀន នៅតាមក្រុង-ស្រុក-ខណ្ឌដែលមិនទាន់បានបំប៉ន
- បង្កើនការផ្សព្វផ្សាយដល់សហគមន៍ និងជួយព្យាបាលកុមារពិការ ព្រមទាំង ផ្តល់ឧបករណ៍ជំនួយ
- ស្នើសុំដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ជួយផ្តល់ថវិកាគាំទ្រដល់ការអប់រំកុមារមានពិការភាព មកកាន់នាយកដ្ឋានអប់រំពិសេស។

ជាចុងបញ្ចប់ លោក ទឹម សាហែន បានធ្វើសេចក្តីសន្និដ្ឋានថា ការអនុវត្តកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព មានការរីកចម្រើនជាបន្តបន្ទាប់ ដោយមានកិច្ចខិតខំប្រឹងប្រែងពីមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងមានការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីអង្គការជាតិ និងដៃគូពាក់ព័ន្ធ។ ចាប់ពីពេលនេះតទៅ កុមារជួបការលំបាក ជាពិសេសកុមារមានពិការភាព នឹងបានទទួលការអប់រំគ្រប់ៗគ្នា និងទទួលបានការអប់រំប្រកបដោយសមធម៌ គុណភាព និងប្រសិទ្ធភាព។

### 2.2. បទបង្ហាញសង្ខេបអំពីការប្រព្រឹត្តិទៅរបស់វិទ្យាស្ថានជាតិអប់រំពិសេស ដោយលោក វន វី នាយករងវិទ្យាស្ថានជាតិអប់រំពិសេស

ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ វិទ្យាស្ថានជាតិអប់រំពិសេស សហការជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានា បានរៀបចំគោលនយោបាយ និងផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ឆ្នាំ២០១៩-២០២៣។ គោលនយោបាយនេះបានកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការអប់រំបរិយាបន្ន ដើម្បីលើកស្ទួយសិទ្ធិរបស់ជនដែលមានសេក្តីត្រូវការពិសេស ឲ្យទទួលបានការអប់រំពេញមួយជីវិត ប្រកបដោយ គុណភាព បរិយាបន្ន និងសមធម៌។

វិទ្យាស្ថានជាតិអប់រំពិសេសត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១១៧ អនក្រ.បក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ និងប្រកាសលេខ ១៣៨ អយក.ប្រក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះវិទ្យាស្ថានជាតិអប់រំពិសេស។

វិទ្យាស្ថានជាតិអប់រំពិសេស (វ.ជ.អ.ព) មាននាយិកា ១ រូប និងនាយករងពីររូប និងបុគ្គលិកចំនួន៣៩ នាក់។ វ.ជ.អ.ព មានការិយាល័យចំនួន ២ និងដេប៉ាតឺម៉ង់ចំនួន ៤ ដែលរួមមាន ការិយាល័យរដ្ឋបាលបុគ្គលិក និងផែនការ ការិយាល័យសិក្សា និងវិក្រឹតការ ដេប៉ាតឺម៉ង់ គ ថ្លង់ ដេប៉ាតឺម៉ង់ពិការភ្នែក ដេប៉ាតឺម៉ង់ខ្សោយសតិបញ្ញា និងដេប៉ាតឺម៉ង់ស្រាវជ្រាវ ព័ត៌មានវិទ្យា និងបណ្ណាល័យ។

វិទ្យាស្ថានជាតិអប់រំពិសេស មានតួនាទី និងភារកិច្ច បណ្តុះបណ្តាលគ្រូបង្រៀន និងវិក្រឹត្យការបុគ្គលិកអប់រំគ្រប់កម្រិតសិក្សាសម្រាប់សិស្សពិការភ្នែក និងសិស្សគ ថ្លង់ និងខ្សោយសតិបញ្ញា អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំគ្រប់កម្រិតសិក្សាសម្រាប់ជនមានពិការភាព អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងវិក្រឹត្យការឲ្យស្របតាមស្តង់ដារសមត្ថភាព គុណវុឌ្ឍិជាតិ និងទីផ្សារការងារសម្រាប់ជនមានពិការភាព ស្រាវជ្រាវ និងអភិវឌ្ឍសញ្ញាណថ្មី ផ្នែកភាសាសញ្ញាខ្មែរ ឧបករណ៍ជំនួយ និងសម្ភារៈឧបទេសនានា

សម្រាប់បង្រៀនសិស្សពិការភ្នែក គ ថ្លង់ និងខ្សោយសតិបញ្ញា កៀរគរធនធានពីប្រភពផ្សេងៗសម្រាប់គាំទ្រការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអប់រំជនមានពិការភាព និងទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

កន្លងមក វិទ្យាស្ថានជាតិអប់រំពិសេស បានធ្វើការបណ្តុះបណ្តាលគរុសិស្សជំនាន់ទី១ ចំនួន ១៨ នាក់ ស្រី ១៤ នាក់ ដែលនៅក្នុងនោះ ជំនាញបង្រៀនសិស្សគ ថ្លង់ មានចំនួន ១០ នាក់ ស្រី ៨ នាក់ និងជំនាញបង្រៀនសិស្សពិការភ្នែក មានចំនួន ៨ នាក់ ស្រី ៦ នាក់។ វិទ្យាស្ថានជាតិអប់រំពិសេស ក៏បានអនុវត្តវគ្គវិក្រឹតការបណ្តុះបណ្តាលគ្រូបង្រៀនសិស្ស គ ថ្លង់ និងពិការភ្នែក ដែលមកពីវិទ្យាល័យអប់រំពិសេសទាំងប្រាំ (ច្បារអំពៅ ភ្នំពេញថ្មី កំពង់ចាម សៀមរាប និងបាត់ដំបង) វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង សាលាគរុកោសល្យភូមិភាគខេត្តកំពង់ចាម សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាម និងសាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប បានចំនួន ៥ លើក ដែលមានសិក្ខាកាមចំនួន ១៦៥ នាក់ ស្រី ៥៨ នាក់ និងមានបុគ្គលិកមានពិការភាពចំនួន ២២ នាក់ ស្រី ៧ នាក់។ ជាមួយគ្នានេះផងដែរ វិទ្យាស្ថានជាតិអប់រំពិសេសក៏បានផ្តល់ការគាំទ្រដល់ការបកប្រែភាសាសញ្ញាដល់សិស្ស គ ថ្លង់ ដែលកំពុងសិក្សានៅសកលវិទ្យាល័យអាស៊ីអឺរ៉ុប និងមនុស្សថ្លង់ដែលកំពុងស្វែងរកការងារធ្វើ ឬកំពុងសិក្សាវិជ្ជាជីវៈនៅតាមស្ថានីយ៍ទូរទស្សន៍នានានៅក្នុងប្រទេសកម្ពុជាផងដែរ ដូចជា ស្ថានីយ៍ទូរទស្សន៍បាយ័ន ស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ស្ថានីយ៍ទូរទស្សន៍ប៉ុស្តិ៍លេខ ៣ ប៉ុស្តិ៍លេខ ៨ ប៉ុស្តិ៍លេខ ៩ ស្ថានីយ៍ទូរទស្សន៍អាស៊ីអាគ្នេយ៍ និងស្ថានីយ៍ទូរទស្សន៍ផ្សេងៗទៀតផងដែរ។ លើសពីនេះទៀត វិទ្យាស្ថានជាតិអប់រំពិសេសបានផលិតសៀវភៅភាសាសញ្ញាកម្ពុជា (បទានុក្រមគ្រប់មុខវិជ្ជា ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៧) សៀវភៅអក្សរប្រៃយ៍ខ្មែរគ្រប់មុខវិជ្ជាចាប់ពីថ្នាក់មត្តេយ្យរហូតដល់សាកលវិទ្យាល័យ និងចងក្រងឯកសារសម្រាប់បណ្តុះ-បណ្តាល និងវិក្រឹតការគ្រូបង្រៀន។

លើសពីនេះទៀត វិទ្យាស្ថានជាតិអប់រំពិសេសមានផែនការបណ្តុះបណ្តាលគរុសិស្សជំនាន់ទី២ បន្តការងារអភិវឌ្ឍសមត្ថភាពបុគ្គលិកនៅក្នុងវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេស អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលផ្នែកខ្សោយសតិបញ្ញា ចងក្រងឯកសារផ្នែកភាសាសញ្ញា និងអក្សរប្រៃយ៍ខ្មែរ ស្រាវជ្រាវវិធីសាស្ត្រថ្មីៗក្នុងការបង្រៀនសិស្សពិការភ្នែក គ ថ្លង់ និងខ្សោយសតិបញ្ញា។

## 2.3. ការបញ្ចាំងវីឌីអូ និងការណែនាំអំពីកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង

លោក អ៊ូច គីម តំណាងអង្គការ RDI នៅក្នុងគម្រោង All Children Reading in Cambodia បានបញ្ចាំង កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង ត្រូវបានក្រសួងអប់រំដាក់ឲ្យប្រើប្រាស់នៅក្នុងខេត្តកំពង់ធំកាលពីឆ្នាំសិក្សាមុន និងបានបន្តអនុវត្តមកដល់ឆ្នាំសិក្សានេះ និងមានការពង្រីកការអនុវត្តនៅក្នុងខេត្តគោលដៅមួយចំនួនទៀតផងដែរ។ គម្រោង All Children Reading in Cambodia ដោយមានការគាំទ្រថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ថា USAID កំពុងធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការដៃគូដើម្បីអភិវឌ្ឍកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងដើម្បីពង្រឹងលទ្ធផលនៃការសិក្សាសម្រាប់សិស្សានុសិស្សទាំងអស់ ចាប់ពីថ្នាក់មត្តេយ្យកម្រិតខ្ពស់រហូតដល់ថ្នាក់ទី២ នៅក្នុងមុខវិជ្ជា

ភាសាខ្មែរ។ ដោយលោក អ៊ុច គីម បានបង្ហាញតែផ្នែកតូចមួយនៃកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងនោះប៉ុណ្ណោះ នោះគឺសៀវភៅរឿង ដែលសៀវភៅរឿងនេះត្រូវបានបែងចែកជាពីរប្រភេទ គឺសៀវភៅរឿងខ្លីដែលមាន ៣០ ចំណងជើង និងសៀវភៅរឿងប្រើញាណចម្រុះចំនួន ១១ ចំណងជើង សរុបមានចំនួន ៤១ ចំណងជើង ហើយសៀវភៅរឿងទាំងនេះក៏ត្រូវបានបង្កើតឡើងជាអក្សរប្រែយ៍ខ្មែរផងដែរសម្រាប់សិស្សពិការភ្នែកផងដែរ។ លោក អ៊ុច គីម បានបង្ហាញខិត្តប័ណ្ណផ្សព្វផ្សាយអំពីសៀវភៅរឿងទាំង ៤១ ចំណងជើងនេះ។ លើសពីនេះទៀត សៀវភៅរឿងទាំង ៤១ ចំណងជើងនេះក៏ត្រូវបានបង្កើតជាវីឌីអូ ដែលមានទាំងសម្លេងសម្រាប់សិស្សពិការភ្នែក និងភាសាសញ្ញាសម្រាប់សិស្ស គ ថ្លង់ និងមានអត្ថបទស្របតាមទំព័រនីមួយៗនៃសៀវភៅរឿង ដែលត្រូវបានយកមកធ្វើជាផ្ទៃរំលេចពីក្រោយ។ សៀវភៅរឿងទាំង ៤១ ចំណងជើងនេះអាចប្រើប្រាស់បានសម្រាប់សិស្សដែលមានវិធីសាស្ត្ររៀនសូត្រខុសៗគ្នា សម្រាប់អ្នកដែលមើលមិនឃើញ ពួកគេអាចធ្វើការស្តាប់សម្លេង និងសម្រាប់អ្នកដែលមើលឃើញប៉ុន្តែស្តាប់មិនឮ ពួកគេអាចមើលភាសាសញ្ញាដែលមាននៅក្នុងវីឌីអូទាំងនោះ ដូច្នេះនេះគឺជាវិឌីអូមួយដែលមានលក្ខណៈបរិយាបន្ន។ ហើយសៀវភៅរឿងដែលត្រូវបានផលិតជាវីឌីអូ ទាំង ៤១ ចំណងជើងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុង Youtube។ វិឌីអូទាំងអស់នេះត្រូវបានដាក់បញ្ចូលគ្នាជា List មួយនៅក្នុង Channel របស់គម្រោង All Children Reading-Cambodia។

លើសពីនេះទៀត កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងត្រូវបានថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ទើបតែបានអនុម័តថ្មីៗ ជាកម្មវិធីថ្នាក់ជាតិរបស់ក្រសួងអប់រំហៅថា កម្មវិធីកុមាររៀនកុមារចេះ ដើម្បីពង្រីកការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងនេះនៅក្នុងក្របខណ្ឌទូទាំងប្រទេស។

ជាចុងបញ្ចប់ លោក អ៊ុច គីម បានបង្ហាញត្រួសៗអំពីគំរូនៃការប្រើប្រាស់វីឌីអូទាំងនោះ។

## 2.4. ការបង្ហាញវីឌីអូអំពីសកម្មភាពជាក់ស្តែងដែលអង្គការក្រៅរដ្ឋាភិបាលបានអនុវត្តកន្លងមក

លោក សៀន កុសល ប្រធានគម្រោងនៃអង្គការ CRS តំណាងឲ្យភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ហៅកាត់ថា NEP បានឡើងបង្ហាញវីឌីអូអំពីសកម្មភាពដែលអង្គការក្រៅរដ្ឋាភិបាលបានធ្វើការនៅលើវិស័យអប់រំ និងពិការភាព ជាបទពិសោធន៍ជាក់ស្តែងកន្លងមក។ នៅក្នុងឱកាសនោះផងដែរ លោក សៀន កុសល ក៏បានលើកឡើងផងដែរថា NEP មាន NGOs ទាំងអស់ ចំនួន ៩ ដែលជា NGO តាមផ្នែកនីមួយៗ ដែល NGOs ទាំងអស់នោះត្រូវបានរួមបញ្ចូលគ្នាបង្កើតបានជាក្រុមការងារស្តីពីការអប់រំ និងពិការភាពដែលដឹកនាំដោយអង្គការ NEP។

## 2.5. បទបង្ហាញស្តីពីការចែករំលែកបទពិសោធន៍អំពីការអនុវត្តការអប់រំបរិយាបន្ននៅថ្នាក់ខេត្ត និងស្រុក

អ្នកគ្រូ ចាន់ វណ្ណៈ តំណាងឲ្យមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ និងក្រុមការងាររបស់អ្នកគ្រូ បានធ្វើការចែករំលែកបទពិសោធន៍អំពីការអនុវត្តការអប់រំបរិយាបន្ននៅថ្នាក់ខេត្ត និងស្រុក នៅក្នុងខេត្តតាកែវ។

គម្រោងបរិយាបន្នរបស់អង្គការ CRS សម្រាប់ថ្នាក់បឋមសិក្សា បានចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ ២០១០ នៅក្នុងស្រុកចំនួន ១ និងត្រូវបានពង្រីកចំនួនស្រុកជាបន្តបន្ទាប់ រហូតដល់ជាចុងក្រោយ គម្រោងនេះត្រូវបានអនុវត្តនៅក្នុងសាលាបឋមសិក្សាចំនួន ២៦ នៅក្នុងស្រុកចំនួន ៥ នៃខេត្តតាកែវ។ គម្រោងនេះត្រូវបានបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៧។

ជាមួយគ្នានោះផងដែរ អង្គការ CRS បានអនុវត្តគម្រោងពីរផ្សេងទៀត ដែលរួមមាន៖

- គម្រោងអន្តរាគមន៍ទាន់ពេលវេលាសម្រាប់កុមារតូច ដែលត្រូវបានអនុវត្តនៅសាលារៀនគោលដៅចំនួន ៩ នៅក្នុងស្រុកគោលដៅចំនួន ៣ នៃខេត្តតាកែវ នៅក្នុងឆ្នាំ២០១៦-២០១៧។ គោលដៅរបស់គម្រោងនេះ គឺដើម្បីកំណត់អត្តសញ្ញាណពិការភាពរបស់កុមារ និងផ្តល់អន្តរាគមន៍ឲ្យបានទាន់ពេលវេលា។ គម្រោងនេះត្រូវបានបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៧។
- គម្រោងអភិវឌ្ឍ និងគាំពារកុមារតូច ត្រូវបានអនុវត្តនៅសាលារៀនគោលដៅចំនួន ៧ នៅក្នុងស្រុកសំរោង ខេត្តតាកែវ សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ និងឆ្នាំសិក្សា ២០១៧-២០១៨។ នៅក្នុងគម្រោងនេះ មានសកម្មភាពចំនួនពីរត្រូវបានអនុវត្ត គឺការផលិតឧបករណ៍កំណត់អត្តសញ្ញាណរបស់កុមារតូច និងការរៀបចំសៀវភៅល្បែងសិក្សា។ គោលដៅរបស់គម្រោងនេះ គឺដើម្បីលើកកម្ពស់គុណភាពការរៀន និងការបង្រៀនកុមារតូចនៅកម្រិតមត្តេយ្យសិក្សា។ គម្រោងនេះត្រូវបានបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៩។

បន្ទាប់ពីគម្រោងនីមួយៗដែលត្រូវបានអនុវត្តដោយអង្គការ CRS បានបញ្ចប់ គម្រោងទាំងនោះត្រូវបានទទួលយកមកអនុវត្តបន្តដោយ មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ដោយបានបង្កើតយន្តការមួយចំនួនសម្រាប់ការអនុវត្តគម្រោងទាំងនោះ ដែលរួមមាន ការបង្កើតក្រុមការងារអប់រំបរិយាបន្ន ដែលមានការទទួលស្គាល់ពីឯកឧត្តមអភិបាលខេត្តតាកែវ ការដាក់បញ្ចូលកម្មវិធីអប់រំបរិយាបន្នទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំប្រចាំខែនៅថ្នាក់មន្ទីរ និងថ្នាក់ការិយាល័យស្រុក ធ្វើការជម្រុញលើកទឹកចិត្តឲ្យសាលារៀនបន្តអនុវត្តគម្រោង ធ្វើកិច្ចសហការជាមួយអង្គការដៃគូ ដូចជា CRS និង CCT និងផ្តល់លិខិតសរសើរដល់បុគ្គល និងអង្គការនានាដែលបានផ្តល់កិច្ចសហការ។ ដោយមានការគាំទ្រ ការលើកទឹកចិត្ត និងការផ្តល់អនុសាសន៍ពីថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត គម្រោងទាំងនោះនៅតែទទួលបានជោគជ័យ និងមានការអនុវត្តសកម្មភាពជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។

ឆ្លៀតក្នុងឱកាសនោះដែរ អ្នកគ្រូ ចាន់ វណ្ណៈ និងក្រុមការងាររបស់អ្នកគ្រូ បានពណ៌នាអំពីសកម្មភាពនានាដែលអ្នកគ្រូ និងក្រុមការងារ បានអនុវត្តនៅក្នុងស្រុកគោលដៅនាពេលកន្លងមកផងដែរ ដែលរួមមាន ការដាក់បញ្ចូលសកម្មភាពអប់រំបរិយាបន្នទៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ ឆ្នាំ ២០១៩-២០២៣ និងផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) ការបំប៉នគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាលសិស្សអំពីការអប់រំបរិយាបន្ន ការចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តនៅតាមសាលារៀនគោលដៅ ជម្រុញការិយាល័យ អយក ស្រុក និងសាលារៀន ឲ្យអនុវត្តការអប់រំបរិយាបន្ន និងដាក់បញ្ចូលការអប់រំបរិយាបន្នចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំប្រចាំខែ ទាំងនៅថ្នាក់ខេត្ត ថ្នាក់

ស្រុក និងថ្នាក់សាលារៀន បង្កើនការផ្សព្វផ្សាយដល់កម្រងសាលារៀន និងអ្នកពាក់ព័ន្ធអំពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងសហការជាមួយអង្គការ CRS និងស្ថាប័នពាក់ព័ន្ធ នាយកដ្ឋានអប់រំពិសេស នៅក្នុងការផលិតឯកសារស្តីពីការកំណត់អត្តសញ្ញាណ និងសៀវភៅណែនាំអំពីល្បែងសិក្សាសម្រាប់ការអប់រំបរិយាបន្ន និងមត្តេយ្យសិក្សា។

ជាលទ្ធផល មន្ទីរអប់រំខេត្តបានអនុវត្តការអប់រំបរិយាបន្ននៅ ២៦ សាលារៀនគោលដៅ ដែលនៅក្នុងនោះមានកុមារពិការចំនួន ១៥០ នាក់ ដែលបានចូលរៀន និងត្រូវបានបញ្ជូនទៅទទួលសេវាព្យាបាល ហើយក្នុងចំណោមសិស្សពិការទាំង ១៥០ នាក់នោះ សិស្សពិការ ១២០ នាក់បានឡើងថ្នាក់។ សាលារៀនគោលដៅនៅក្នុងខេត្ត មានកិច្ចសហការល្អជាមួយសហគមន៍ និងដៃគូអភិវឌ្ឍន៍ មានហេដ្ឋារចនាសម្ព័ន្ធសម្រាប់កុមារពិការ ដូចជា ជម្រាល កន្លែងលាងដៃ បង្គន់អនាម័យ ជាដើម។ ជាមួយគ្នានេះផងដែរ ក្រុមប្រឹក្សាឃុំបានផ្តល់ថវិកាបដិភាគនៅក្នុងផែនការអភិវឌ្ឍឃុំទៅឲ្យសាលារៀន ពាក់ព័ន្ធនឹងការអប់រំបរិយាបន្ន។

អ្នកគ្រូ និងក្រុមការងាររបស់អ្នកគ្រូ បានលើកឡើងថា ទោះបីជាពួកគេទទួលលទ្ធផលល្អៗជាច្រើនក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជា ការចូលរួមរបស់ក្រុមការងារ និងអ្នកពាក់ព័ន្ធនៅតែមានកម្រិត ដោយមានសមាសភាពមួយចំនួនបានអវត្តមាននៅពេលអនុវត្តសកម្មភាព កង្វះថវិកាគាំទ្រដល់ការអនុវត្តការអប់រំបរិយាបន្ន ហើយអាជ្ញាធរ និងអាណាព្យាបាលសិស្សមួយចំនួននៅមិនទាន់យល់ច្បាស់អំពីការអប់រំបរិយាបន្ន។

ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ថ្នាក់ដឹកនាំរបស់មន្ទីរអប់រំខេត្តក៏បានអនុវត្តដំណោះស្រាយនានាផងដែរ ដែលរួមមាន ការពិនិត្យ និងកែសម្រួលសមាសភាពក្រុមការងារ ដាក់បញ្ចូលសកម្មភាពអប់រំបរិយាបន្នទៅក្នុងផែនការប្រតិបត្តិរបស់មន្ទីរ និងការិយាល័យ អយក ស្នើសុំថវិកាពីដៃគូអភិវឌ្ឍសម្រាប់គាំទ្រការអនុវត្តការអប់រំបរិយាបន្នស្របតាមគោលនយោបាយរបស់ក្រសួង និងផ្សព្វផ្សាយអំពីការអប់រំបរិយាបន្នឲ្យបានទូលំទូលាយ។

ជាទិសដៅអនុវត្តបន្ត ថ្នាក់ដឹកនាំមន្ទីរ អយក ខេត្តតាកែវ ជម្រុញការអនុវត្តផែនការសកម្មភាពនៅគ្រប់គ្រឹះស្ថានសិក្សានៅក្នុងខេត្ត បន្តដាក់បញ្ចូលសកម្មភាពអប់រំបរិយាបន្ននៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ជម្រុញការប្រមូល និងគ្រប់គ្រងទិន្នន័យកុមារមានពិការភាព បន្តនិរន្តភាពការអប់រំបរិយាបន្នជាមួយដៃគូអភិវឌ្ឍន៍ នៅពេលដែលអង្គការដៃគូបញ្ចប់គម្រោង និងផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀនថ្នាក់អប់រំបរិយាបន្នដែលមានស្នាដៃល្អ តាមរយៈ ការផ្តល់លិខិតថ្លែងអំណរគុណ និងប័ណ្ណសរសើរ ជាដើម។

## 2.6. បទបង្ហាញស្តីពីការចែករំលែកបទពិសោធន៍អំពីការអនុវត្តការអប់រំបរិយាបន្ននៅថ្នាក់សាលារៀន

ជាបឋម លោក ឯម កាល ជានាយកសាលាបឋមសិក្សាមួយខ្នងនៅក្នុងស្រុកសំរោងខេត្តតាកែវ បានលើកឡើងថា ដោយមានការគាំទ្រពីការិយាល័យ អយក ស្រុក និងមន្ទីរ អយក ខេត្ត គណៈគ្រប់គ្រងសាលារៀនបានបង្កើតក្រុមការងារអប់រំបរិយាបន្ន ដែលក្នុងនោះ សមាសភាពសំខាន់ៗរួមមាន សាលារៀន

ក្រុមប្រឹក្សាឃុំ មេភូមិ ព្រះសង្ឃ និងមណ្ឌលសុខភាព ជាដើម។ ទន្ទឹងនឹងនេះ គណៈគ្រប់គ្រងសាលារៀនបានដាក់បញ្ចូលសកម្មភាពការអប់រំបរិយាបន្នទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងផែនការប្រតិបត្តិ ហើយគណៈគ្រប់គ្រងសាលារៀនក៏បានពង្រឹងការពិនិត្យតាមដាន និងជម្រុញការអនុវត្តផងដែរ។

ឆ្លៀតក្នុងឱកាសនោះ លោកនាយកក៏បានលើកឡើងអំពីសកម្មភាពនានាដែលគណៈគ្រប់គ្រងសាលារៀនបានអនុវត្តនាពេលកន្លងមកផងដែរ។ សាលារៀនបានរៀបចំសកម្មភាពបំប៉នគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន។ សាលារៀនបានអនុវត្តយុទ្ធនាការប្រមូលកុមារ ជាពិសេស កុមារពិការ ឲ្យចូលរៀន។ សាលារៀនបានធ្វើការកំណត់អត្តសញ្ញាណកុមារពិការ។ សាលារៀនបានចុះពិនិត្យតាមដាន និងជម្រុញការអនុវត្ត និងដាក់បញ្ចូលការអប់រំបរិយាបន្នទៅក្នុងរបៀបវារៈប្រជុំប្រចាំខែ។ សាលារៀនបានបញ្ចូលល្បែងសិក្សា និងល្បែងសេរីទៅក្នុងការអប់រំបរិយាបន្ន លោកគ្រូ អ្នកគ្រូ បានរំលេចសកម្មភាពជួយកុមារមានពិការភាពនៅក្នុងកិច្ចតែងការបង្រៀន គ្រូបង្រៀនបានប្រើប្រាស់សម្ភារឧទេស ល្បែងសិក្សា និងល្បែងសេរីដែលសមស្រប រៀបចំកន្លែងអង្គុយ តាមប្រភេទពិការភាព និងតាមភាពសមស្រប គ្រូបង្រៀន និងអ្នកសិក្សាដែលមិនពិការលើកទឹកចិត្ត និងជួយសិស្សមានពិការភាព។ គណៈគ្រប់គ្រងសាលារៀនបានដាក់ហិបមូលនិធិនៅតាមវត្ត ដើម្បីផ្តល់ការគាំទ្រដល់ការអប់រំបរិយាបន្ន។ គណៈគ្រប់គ្រងសាលារៀនបានដាក់បញ្ចូលការអប់រំបរិយាបន្នទៅក្នុងកម្មវិធីវិនិយោគឃុំ។

ទន្ទឹងនឹងសកម្មភាពជាច្រើន ដែលសាលារៀន និងលោកគ្រូ អ្នកគ្រូបានអនុវត្ត ពួកគេក៏ទទួលបានលទ្ធផលល្អៗមកវិញមួយចំនួនផងដែរ ដែលរួមមាន កុមារមានពិការភាពបានឡើងថ្នាក់ទៅតាមកម្រិតថ្នាក់រៀននីមួយៗ កុមារមានពិការភាពទទួលបានឧបករណ៍ជំនួយ និងថ្នាំព្យាបាល សុខភាពរបស់កុមារមានពិការភាពមានភាពល្អប្រសើរឡើង កុមារមានពិការភាពបានចូលរួមនៅគ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀនជាមួយកុមារមិនពិការ។

ទន្ទឹមនឹងការទទួលបានលទ្ធផលល្អៗ សាលារៀនក៏ប្រឈមមុខនឹងបញ្ហាប្រឈមមួយចំនួនផងដែរ ដែលរួមមាន លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងពុំទាន់មានវិធីសាស្ត្រ និងសមត្ថភាពពេញលេញនៅក្នុងការអប់រំបរិយាបន្ន សិស្សមានពិការភាពច្រើនប្រភេទខុសៗគ្នានៅក្នុងថ្នាក់រៀនតែមួយ កុមារមានពិការភាពអវត្តមានញឹកញាប់ ដោយសារជីវភាពខ្វះខាត ឬឪពុកម្តាយលែងលះគ្នា ជាដើម។ លើសពីនេះទៀត អាណាព្យាបាលពុំទាន់ផ្តល់ការសហការដល់សាលារៀនឲ្យបានល្អប្រសើរ នៅក្នុងការបញ្ជូនកុមារទៅទទួលសេវាព្យាបាល។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះ សាលារៀនក៏មានដំណោះស្រាយនានាផងដែរ ដែលរួមមាន ការជម្រុញ និងលើកទឹកចិត្តគ្រូបង្រៀនថ្នាក់អប់រំបរិយាបន្ន ផ្តល់ការប្រឹក្សាដល់អាណាព្យាបាលឲ្យយល់អំពីតម្លៃនៃការសិក្សា រៀបចំសិស្សមានពិការភាព ស្របតាមអាយុ និងកម្រិតថ្នាក់។

ដើម្បីរក្សាឲ្យបាននូវនិរន្តរភាពនៃការអនុវត្តការអប់រំបរិយាបន្ននេះ សាលារៀនបានដាក់ចេញនូវទិសដៅអនុវត្តបន្តមួយចំនួន ដែលរួមមាន ការដាក់បញ្ចូលសកម្មភាពអប់រំបរិយាបន្ននៅក្នុងផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដាក់បញ្ចូលសកម្មភាពអប់រំបរិយាបន្នទៅក្នុងកម្មវិធីវិនិយោគឃុំ បន្តបំប៉នសមត្ថភាពគ្រូបង្រៀន និងគណៈគ្រប់គ្រងលើការអប់រំបរិយាបន្ន និងបន្តជម្រុញគ្រូបង្រៀនឲ្យអនុវត្តការអប់រំបរិយាបន្ន និងដាក់បញ្ចូលនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំប្រចាំខែ។ លើសពីនេះទៀត សាលារៀននឹងបន្តធ្វើការគៀរគរថវិកា និងស្វែងរកសប្បុរសជន ដើម្បីជួយគាំទ្រការអប់រំបរិយាបន្ន បន្តជម្រុញលើកទឹកចិត្តកុមារមានពិការភាពឲ្យមករៀនឲ្យបានទៀងទាត់ ផ្តល់ការប្រឹក្សាយោបល់ដល់មាតាបិតាកុមារមានពិការភាពឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីការអប់រំបរិយាបន្ន បន្តសហការជាមួយសហគមន៍ និងដៃគូអភិវឌ្ឍ និងបញ្ជូនកុមារមានពិការភាពទៅទទួលសេវាព្យាបាល។

## 2.7. បទបង្ហាញអំពីវឌ្ឍនភាពនៃសាលាបឋមសិក្សាទួលគោក

ជាដំបូង លោក ផាត សុខា នាយកសាលាបឋមសិក្សាទួលគោក បានរៀបរាប់ត្រួសៗអំពីស្ថានភាពរបស់សាលាបឋមសិក្សាទួលគោក។ សាលាបឋមសិក្សាទួលគោក មានទំហំ ២៩.៦០៩ ម៉ែត្រក្រឡា និងមានទីតាំងស្ថិតនៅជីឡូត៍លេខ ៧ តាមបណ្តោយមហាវិថី គីម អ៊ីលស៊ុង ភូមិ ១០ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក។ សាលាបឋមសិក្សាទួលគោកមានអគារសិក្សាចំនួន ១៣ ខ្នង មានបន្ទប់រៀនចំនួន ៨០ បន្ទប់ មានគ្រូបង្រៀនសរុបចំនួន ១២៣ នាក់ ស្រី ១០៤ នាក់ និងមានសិស្សសរុបចំនួន ២.៧៦៨ នាក់ ស្រី ១.៣០២ នាក់។

នៅក្នុងឆ្នាំ២០០៨-២០០៩ ដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា សាលារៀនទន្សាយត្រូវបានបង្កើតឡើងនៅក្នុងសាលាបឋមសិក្សាទួលគោក ដោយនៅក្នុងឆ្នាំសិក្សាដំបូង មានសិស្សមានពិការភាពតែ ១៦ នាក់ ស្មើនឹងមួយថ្នាក់ប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នចំនួនសិស្សមានពិការភាពបានកើនឡើងរហូតដល់ ១៨៩ នាក់។ ទោះបីជាកុមារមានពិការភាពមិនអាចស្រូបយកចំណេះដឹងបាន ១០០% ដូចកុមារធម្មតាក៏ដោយ ប៉ុន្តែយ៉ាងហោចណាស់យើងបានជួយសម្រួលបន្ទុករបស់មាតាបិតារបស់កុមារមានពិការភាពដែលពួកគាត់អាចយកពេលវេលាដែលពួកគាត់ត្រូវមើលថែទាំកូនពេញមួយថ្ងៃទៅធ្វើការ និងប្រកបមុខរបរផ្សេងៗដើម្បីចិញ្ចឹមជីវិត ហើយនៅពេលដែលកុមារមកដល់សាលារៀន សាលារៀនមានលោកគ្រូ អ្នកគ្រូដែលមានជំនាញ និងមានការយកចិត្តទុកដាក់ចំពោះការមើលថែទាំសិស្ស។ ទោះបីជាកុមារមានពិការភាពរៀននៅក្នុងថ្នាក់សមាហរណកម្មដាច់ដោយឡែកពីសិស្សគ្មានពិការភាព ប៉ុន្តែនៅពេលចេញលេង ពួកគាត់នៅតែអាចរត់លេងជាមួយសិស្សគ្មានពិការភាពបាន និងមានគ្រូបង្រៀននៅតាមមើលថែទាំពួកគាត់នៅម៉ោងចេញលេងនោះផងដែរ។ នៅក្នុងថ្នាក់សមាហរណកម្ម មានសិស្សចំនួន ៧-១០ នាក់ និងមានគ្រូបង្រៀន ២ នាក់។ នៅក្នុងសាលាបឋមសិក្សាទួលគោក មានការហាត់ប្រាណរៀងរាល់ថ្ងៃអង្គារ ដែលសិស្សានុសិស្សគ្រប់រូបត្រូវពាក់ឯកសណ្ឋានពណ៌ក្រហម ដែលកុមារមានពិការភាពក៏ត្រូវតែពាក់ឯកសណ្ឋានពណ៌ក្រហមដែរ។

បន្ទាប់មក លោកនាយកបានលើកឡើងអំពីផលវិបាកមួយចំនួនដែលសាលាបឋមសិក្សានេះបានជួបប្រទះនៅអំឡុងរយៈពេលដំបូងនៃការអនុវត្តកម្មវិធីអប់រំបរិយាបន្ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសាលារៀន (សិស្សចម្រុះ) កង្វះខាតគ្រូបង្រៀន កង្វះខាតជំនាញ និងវិធីសាស្រ្តក្នុងការបង្រៀនសិស្សមានពិការភាព និងការរើសអើងពីសហគមន៍។ ទន្ទឹមនឹងនោះ លោកនាយកក៏បានលើកឡើងអំពីលទ្ធផលវិជ្ជមានជាច្រើនដែលសាលាបឋមសិក្សាទួលគោកទទួលបានផងដែរ ដែលរួមមាន ការទទួលបានការគាំទ្រពីក្រសួងអប់រំ ចំនួនថ្នាក់រៀនមានការកើនឡើង ចំនួនសិស្សមានការកើនឡើង ចំនួនគ្រូបង្រៀនមានការកើនឡើង ហេដ្ឋារចនាសម្ព័ន្ធមានភាពល្អប្រសើរឡើង (ទីជម្រាល បន្ទប់ទឹក...) អាណាព្យាបាល និងកុមារពិការ ផ្តល់កិច្ចសហការ និងការគាំទ្រ កុមារមានភាពរីកចម្រើន និងលូតលាស់បានល្អ មានការថយចុះនៃការរើសអើងនៅក្នុងសហគមន៍ និងទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ផ្នែកថវិកា បច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធ ជាដើម។ ទោះបីជាសាលារៀននេះទទួលបានលទ្ធផលវិជ្ជមានជាច្រើនក៏ដោយ ក៏សាលារៀននៅតែមានបញ្ហាប្រឈមមួយចំនួនដែរ ដូចជា កង្វះខាតគ្រូបង្រៀនសម្រាប់កុមារពិការសតិបញ្ញា កង្វះខាតថ្នាក់រៀន ដោយនៅក្នុងថ្នាក់រៀននីមួយៗមានសិស្សច្រើនពេក និងពិបាកបង្រៀន ហើយប្រាក់លើកទឹកចិត្តសម្រាប់គ្រូបង្រៀនកុមារពិការសតិបញ្ញាមិនទាន់បានបំពេញតាមតម្រូវការជាក់ស្តែង។ ជាមួយគ្នានេះដែរ លោកនាយកបានសំណូមពរឲ្យមានការបើកចិត្តឲ្យទូលាយក្នុងការទទួលយកកុមារពិការ និងស្វែងយល់អំពីពួកគាត់ បង្កើនថ្នាក់រៀននៅតាមសាលារៀនផ្សេងៗទៀត បង្កើនគ្រូបង្រៀនជំនាញបង្រៀនកុមារពិការនៅតាមសាលារៀនផ្សេងៗទៀតឲ្យបានច្រើន ដើម្បីឲ្យកុមារពិការបានចូលរៀនដូចកុមារធម្មតាដែរ។ ទន្ទឹមនឹងនោះ លោកនាយកក៏បានសំណូមពរឲ្យមានការបន្ថែមប្រាក់លើកទឹកចិត្ត និងប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្រៀន និងសាលារៀនដែលមានថ្នាក់អប់រំកុមារពិការផងដែរ។ លោកនាយកបានសំណូមពរឲ្យបញ្ឈប់ការរើសអើងចំពោះកុមារពិការ ដោយចាប់ផ្តើមពីជំនាន់របស់យើង និងបន្តទៅជំនាន់ក្រោយៗទៀត។ ជាចុងបញ្ចប់ លោកនាយកបានថ្លែងអំណរគុណដល់ក្រសួងអប់រំ អង្គការសាលារៀនទន្សាយ អង្គការដៃគូនានាដែលបានឧបត្ថម្ភគាំទ្រឲ្យសាលាបឋមសិក្សាទួលគោកបានដំណើរការថ្នាក់សមាហរណកម្មរយៈពេល ១២ឆ្នាំ បានយ៉ាងរលូន និងទទួលបានជោគជ័យ។

## 2.8. បទបង្ហាញចែករំលែកបទពិសោធន៍អំពីការបង្រៀនកុមារមានពិការភាពផ្នែកសតិបញ្ញា

អ្នកគ្រូ ញ៉ែម ណារី ជាគ្រូបង្រៀនកុមារពិការសតិបញ្ញានៅសាលាបឋមសិក្សាទួលគោក អស់រយៈពេលជិត ២០ឆ្នាំ មកហើយ បានបង្ហាញចំណាប់អារម្មណ៍ និងពណ៌នាអំពីបទពិសោធន៍មួយចំនួនរបស់អ្នកគ្រូនៅក្នុងការបង្រៀននេះ។ អ្នកគ្រូបានលើកឡើងថា ការងាររបស់អ្នកគ្រូបានជួបប្រទះនឹងការពិបាកជាច្រើន ដោយសារតែកុមារពិការសតិបញ្ញាមិនអាចធ្វើការទំនាក់ទំនងបានដូចក្មេងធម្មតានោះទេ អ្នកគ្រូត្រូវបង្រៀនពួកគេអំពីវិធីជួយខ្លួនឯង បង្ហាត់ពួកគាត់ឲ្យចេះមើល ចេះអាន ចេះទំនាក់ទំនងជាមួយអ្នកដទៃ និងចេះនិយាយ។ អ្នកគ្រូបានលើកឡើងថា ការបង្រៀនកុមារពិការសតិបញ្ញាមានការលំបាកខ្លាំងណាស់ ដោយអ្នកគ្រូត្រូវបង្រៀនពីរពេលក្នុងមួយថ្ងៃ និងទទួលបានបៀវត្សរ៍តិចតួចខ្លាំងណាស់។ កាលពីប៉ុន្មានឆ្នាំមុន អ្នកគ្រូធ្លាប់លាឈប់ពីការងារនេះ ប៉ុន្តែដោយសារតែកង្វះខាតគ្រូបង្រៀនដែលមានជំនាញ និងដោយទឹកចិត្តស្រលាញ់កុមាររបស់អ្នកគ្រូ អ្នកគ្រូក៏បានត្រឡប់មកបង្រៀនកុមារទាំងនោះវិញ។ អ្នកគ្រូក៏

បានបញ្ជាក់អំពីមូលហេតុដែលអ្នកគ្រូត្រឡប់មកបង្រៀនកុមារពិការសតិបញ្ញាវិញផងដែរ ដោយអ្នកគ្រូបានថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរក្សាទុកក្របខណ្ឌគ្រូបង្រៀនជូនអ្នកគ្រូ។ ហើយមូលហេតុចម្បងមួយទៀត គឺការលើកទឹកចិត្តពីមាតាបិតាសិស្ស ដែលបានបង្ហាញអំពីភាពសប្បាយរីករាយ និងការថ្លែងអំណរគុណដល់អ្នកគ្រូ បន្ទាប់ពីពួកគាត់បានមើលឃើញការវិវត្តរបស់កូនៗរបស់ពួកគាត់។

អ្នកគ្រូក៏បានលើកឡើងអំពីភាពរើសអើងដែលអ្នកគ្រូបានជួបប្រទះផងដែរ ដោយអ្នកគ្រូបានលើកឡើងថា ការរើសអើងមិនត្រូវតែកើតឡើងចំពោះសិស្សពិការតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏កើតឡើងចំពោះគ្រូបង្រៀនសិស្សពិការផងដែរ។ អ្នកគ្រូបានលើកឧទាហរណ៍ថា ធ្លាប់មានភ្ញៀវមកកាន់បន្ទប់បង្រៀនរបស់អ្នកគ្រូ ដោយបានបង្ហាញនូវឥរិយាបថមិនពេញចិត្ត និងសួរអ្នកគ្រូថា "តើអ្នកណាឲ្យយកសិស្សពិការមករៀននៅសាលាបឋមសិក្សា?"

ទន្ទឹមនឹងនេះ អ្នកគ្រូក៏បានលើកឡើងផងដែរ អំពីការយល់ដឹងកាន់តែល្អប្រសើរឡើងរបស់មាតាបិតាសិស្ស ពាក់ព័ន្ធនឹងការអប់រំបរិយាបន្ន។ ដោយបានមើលឃើញការវិវត្តនៃការចេះជួយខ្លួនឯង និងការប្រែប្រួលនៃឥរិយាបថរបស់កុមារពិការនៅក្នុងផ្លូវវិជ្ជមាន បន្ទាប់ពីបានចូលរៀននៅក្នុងសាលារៀនទន្សាយនៅក្នុងឆ្នាំសិក្សាកន្លងមករួចហើយនោះ មានមាតាបិតាជាច្រើនអ្នកបានបញ្ជូនកូនៗដែលមានពិការភាពរបស់ពួកគាត់ឲ្យមកចូលរៀននៅសាលារៀនទន្សាយ។

ឆ្លៀតក្នុងឱកាសនោះដែរ អ្នកគ្រូបានសំណូមពរឲ្យមានការបង្កើនថ្នាក់រៀនសម្រាប់កុមារមានពិការភាពឲ្យបានច្រើន នៅគ្រប់ទីកន្លែង ហើយអ្នកគ្រូក៏បានសំណូមពរឲ្យមានគ្រូបង្រៀនដែលមានបច្ចេកទេស និងមានជំនាញគរុកោសល្យ ចូលបង្រៀនថ្នាក់អប់រំបរិយាបន្នបន្ថែមទៀតផងដែរ។ ជាចុងក្រោយ អ្នកគ្រូបានសំណូមពរឲ្យមានការដំឡើងប្រាក់ឧបត្ថម្ភជូនអ្នកគ្រូ ពីព្រោះអ្នកគ្រូត្រូវបង្រៀនពីរពេលក្នុងមួយថ្ងៃ ហើយក្នុងអំឡុងពេលវិស្សមកាល អ្នកគ្រូមិនបានឈប់សម្រាកនោះទេ ពីព្រោះអ្នកគ្រូត្រូវបង្កើតសម្ភារៈសិក្សាសម្រាប់ឆ្នាំសិក្សាបន្ទាប់ទៀត។

## 2.9. បទបង្ហាញអំពីប្រកាសលេខ ១៦៧៧

ឆ្លៀតក្នុងឱកាសនោះដែរ លោក ថោង រិទ្ធី ប្រធាននាយកដ្ឋានអប់រំពិសេស បានធ្វើការបង្ហាញត្រួសៗអំពីប្រកាស លេខ ១៦៧៧។ លោក ថោង រិទ្ធី បានលើកឡើងអំពីជំពូកទី ៥ ដែលចែងអំពីការកំណត់និយាមសិស្ស-ថ្នាក់។ នៅក្នុងប្រការទី១៥ នៃជំពូកទី៥ បានចែងថា "សិស្សពិការភ្នែក គ ថ្លង់ និងពិការសតិបញ្ញា មានអាយុចាប់ពី ៣ ឆ្នាំ ដល់ ៥ ឆ្នាំ មានសិទ្ធិចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យសិក្សានៅសាលាអប់រំពិសេស ឬវិទ្យាល័យអប់រំពិសេស ហើយសិស្សពិការភ្នែក គ ថ្លង់ និងពិការសតិបញ្ញា មានអាយុចាប់ពី ៦ ឆ្នាំ ដល់ ១៤ ឆ្នាំ មានសិទ្ធិចុះឈ្មោះចូលរៀនថ្នាក់ទី១ នៅសាលាអប់រំពិសេស ឬវិទ្យាល័យអប់រំពិសេស"។ ប្រការទី១៦ ចែងថា "សិស្សពិការភ្នែក គ ថ្លង់ និងពិការសតិបញ្ញា ត្រូវបានកំណត់និយាមចាប់ពី ៣ នាក់ ដល់ ១០ នាក់ក្នុងមួយថ្នាក់ សម្រាប់ថ្នាក់រៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្មនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ កម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។" ក្នុង

ករណីសិស្សមានពិការភាព មានចំនួន ១១ នាក់ឡើងទៅ ត្រូវបំបែកជាពីរថ្នាក់។ សិស្សពិការភ្នែក គ ថ្លង់ និងពិការសតិបញ្ញា ត្រូវចូលរៀនមួយពេលទៀតនៅគ្រឹះស្ថានសិក្សាសាធារណៈរហូតដល់បញ្ចប់គ្រប់ភូមិសិក្សា។ មានន័យថា ពួកគាត់ត្រូវរៀនពីរពេល ប្រសិនបើពួកគាត់រៀនពេលព្រឹកនៅថ្នាក់សមាហរណកម្ម នៅពេលរសៀល ពួកគាត់ត្រូវរៀនមួយពេលទៀត នៅថ្នាក់ធម្មតា ជាមួយសិស្សមិនពិការ។ ពាក់ព័ន្ធនឹងគ្រូបង្រៀន ប្រការទី១៧ ចែងថា គ្រូបង្រៀនពិការភ្នែក និង គ ថ្លង់ម្នាក់ ត្រូវបង្រៀនមួយថ្នាក់ នៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម ដោយបន្ថែមគ្រូជំនួយម្នាក់ដែលមិនពិការ។ គ្រូបង្រៀនមិនពិការម្នាក់ដែលមានជំនាញភាសាសញ្ញា ឬអក្សរប្រៃយ៍ ត្រូវបង្រៀនសិស្សមួយថ្នាក់ ដោយពុំមានគ្រូជំនួយ។ គ្រូបង្រៀនមិនពិការម្នាក់ដែលមានជំនាញផ្នែកពិការសតិបញ្ញា ត្រូវបង្រៀនសិស្សមួយថ្នាក់ដោយមានគ្រូពិការសតិបញ្ញាម្នាក់ (អាចជាប្រធានថ្នាក់ ឬសិស្សដែលរៀននៅថ្នាក់ខ្ពស់ជាង) ជាគ្រូជំនួញ។

## 2.10. បទបង្ហាញស្តីពីបរិយាកាសសាលារៀនបរិយាបន្ន

ឆ្លៀតនៅក្នុងឱកាសនោះ លោក ទឹម សាហែន អនុប្រធាននាយកដ្ឋានអប់រំពិសេស បានធ្វើបទ-បង្ហាញសង្ខេបអំពីធាតុនានាដែលសាលាអប់រំបរិយាបន្ននៅតាមរាជធានី-ខេត្ត ត្រូវមាន ដែលរួមមាន៖

- ឥរិយាបថរបស់គ្រូបង្រៀន៖ លោកគ្រូ អ្នកគ្រូ ត្រូវមានឥរិយាបថវិជ្ជមានចំពោះកុមារពិការ។
- វិធីសាស្ត្របង្រៀនកុមារពិការ៖ តើគ្រូបង្រៀនត្រូវមានវិធីសាស្ត្រអ្វីខ្លះដើម្បីបង្រៀនកុមារពិការ? ដើម្បីឆ្លើយតបទៅនឹងសំណួរនេះ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់វគ្គបណ្តុះបណ្តាលជាច្រើនស្តីពីការអប់រំបរិយាបន្ន។
- គោលវិធីបង្រៀន៖ យើងត្រូវមានគោលវិធីសម្រាប់បង្រៀន ដោយដាក់កុមារពិការ និងកុមារមិនពិការចូលគ្នាដើម្បីអនុវត្តសកម្មភាពនៃការបង្រៀនរួមគ្នា។
- វិធីសាស្ត្របង្រៀនត្រូវតែមានភាពបត់បែន ដើម្បីធ្វើឲ្យកុមារពិការចូលរួមនៅគ្រប់សកម្មភាពនៃការបង្រៀន។
- ឧបករណ៍ជំនួយ និងសម្ភារៈបង្រៀន៖ គ្រូបង្រៀនត្រូវតែពិនិត្យមើលថាតើឧបករណ៍ជំនួយមានភាពសមស្របតាមប្រភេទនៃពិការភាពរបស់កុមារពិការដែរឬទេ និងថាតើសម្ភារៈបង្រៀនបំពេញតាមតម្រូវការរបស់កុមារពិការដែរឬទេ។ នៅក្នុងនាមជាគ្រូបង្រៀនថ្នាក់បរិយាបន្ន យើងត្រូវតែត្រួតពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយ។
- ការចូលរួមរបស់មាតាបិតា និងសហគមន៍៖ ការចូលរួមតែពីសាលារៀន និងគ្រូបង្រៀន មិនអាចធ្វើឲ្យការអប់រំបរិយាបន្នទទួលបានជោគជ័យនោះទេ។
- សាលារៀន និងគ្រូបង្រៀនផ្តល់ការគាំទ្រល្អ៖ គណៈគ្រប់គ្រងសាលារៀនគាំទ្រចំពោះការទទួលយកកុមារពិការឲ្យចូលរៀន និងគ្រូបង្រៀនយកចិត្តទុកដាក់បង្រៀនកុមារពិការ។
- គ្មានសិស្សបោះបង់ការសិក្សា ឬរៀនត្រួតថ្នាក់
- មានស្លាកសញ្ញានាំផ្លូវទៅកាន់សាលារៀន

- សាលាផ្តល់មធ្យោបាយធ្វើដំណើរសម្រាប់កុមារដែលមានបញ្ហាបម្លាស់ទី ដូចជា ឈើច្រត់ ឬរទេះរុញ ជាដើម
- មានស្លាកឈ្មោះសាលារៀន
- ផ្លូវចូលសាលារៀនមានភាពរាបស្មើ និងគ្មានឧបសគ្គ
- សន្តិសុខយាមស្វាគមន៍ និងជួយភ្ញៀវ
- បុគ្គលិកទទួលភ្ញៀវមានភាពកក់ក្តៅ និងរាក់ទាក់
- មានក្តារខៀនព័ត៌មាន ផ្តល់ព័ត៌មានមានប្រយោជន៍សម្រាប់ភ្ញៀវ និងឪពុកម្តាយ
- សាលាមានព្រឹត្តិបត្រ ឬប្រព័ន្ធទំនាក់ទំនងជាមួយឪពុកម្តាយ
- ផ្ទាំងតាំងបង្ហាញអំពីវប្បធម៌ផ្សេងៗដែលមាននៅក្នុងសាលារៀន និងស្នាដៃផ្សេងៗ
- ផ្លូវដើរនៅក្នុងផ្នែកនានានៃសាលារៀនរាបស្មើ និងគ្មានឧបសគ្គ
- ទ្វារធំល្មមសម្រាប់រទេះរុញចេញ-ចូល
- មានជណ្តើរ មានបង្កាន់ដៃ
- មានជម្រាលសមស្រប នៅកន្លែងមានកាំជណ្តើរ
- កាំជណ្តើរមានលាបពណ៌លឿង ឬ ស សម្រាប់កុមារខ្សោយគំហើញ
- មានស្លាកសញ្ញាសម្គាល់ទីតាំងគ្រោះថ្នាក់ (រណ្តៅ)
- មានស្លាកសញ្ញាសម្គាល់បន្ទប់ និងច្រកចេញ-ចូល នៅក្នុងបណ្ណាល័យ ឬបន្ទប់សម្ភារៈ
- ស្លាកសញ្ញាមើលឃើញច្បាស់ល្អ និងអាចយល់បាន។

## 3. កិច្ចពិភាក្សាតុមូលស្តីពីការបង្កើនការវិនិយោគលើការកសាងសមត្ថភាពគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន

កិច្ចពិភាក្សាតុមូលត្រូវបានធ្វើឡើងដោយមានការសម្របសម្រួលពីលោក យិន សៀង សុមេត អ្នកឯកទេសអប់រំនៃអង្គការ Save the Children ដោយមានការផ្តល់កិត្តិយសចូលរួមពីវាយគ្មិនកិត្តិយស ដែលរួមមាន៖

- ឯកឧត្តម ពុត សាមិត អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម ទេព ភិយ្យោរិទ្ធ អគ្គនាយកនៃនាយកដ្ឋានហិរញ្ញវត្ថុ
- ឯកឧត្តម ថោង រិទ្ធី ប្រធាននាយកដ្ឋានអប់រំពិសេស
- លោកស្រី នាង ផល្លា ស្ថាបនិករបស់អង្គការគ្រួសារថ្មី និងជាប្រធានវិទ្យាស្ថានជាតិអប់រំពិសេស
- លោកស្រី ផន សុធា តំណាងនាយកដ្ឋានជំនាញ
- លោក អ៊ិត រិទ្ធិ អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ
- លោកស្រី Satomi តំណាងភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល

ជាកិច្ចចាប់ផ្ដើម ឯកឧត្ដម ពុត សាមិត អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ បានបង្ហាញចំណាប់អារម្មណ៍អំពីកំណែទម្រង់ប្រព័ន្ធអប់រំនៅពីរអាណត្តិចុងក្រោយនេះ ដែលស្ថិតក្រោមការដឹកនាំរបស់ឯកឧត្ដមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន។ ឯកឧត្ដម បានលើកឡើងថា ដោយមើលឃើញថា បញ្ហាគុណភាពអប់រំ គឺជាបញ្ហាចម្បង និងដើម្បីពង្រឹងគុណភាពអប់រំ ឯកឧត្ដមបណ្ឌិតសភាចារ្យបានធ្វើកំណែទម្រង់លើប្រព័ន្ធអប់រំដោយចាប់ផ្ដើមពីការអនុវត្តចតុកោណទីមួយ គឺការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ បន្ទាប់ពីធ្វើកំណែទម្រង់លើការប្រឡងរួចមក យើងបានមើលឃើញប្រព័ន្ធអប់រំរបស់យើងទាំងមូល ថាតើយើងគួរតែកែសម្រួលអ្វីខ្លះនៅក្នុងប្រព័ន្ធអប់រំរបស់យើង។ ដូចដែលអង្គពិធីទាំងមូលបានលើកឡើងរួចមកហើយ នៅក្នុងប្រព័ន្ធអប់រំ បញ្ហាសមត្ថភាពគ្រូបង្រៀន គឺជាកត្តាចម្បង បន្ទាប់មកទៀត គឺកម្មវិធីសិក្សា ការបណ្ដុះបណ្ដាល ការងារគ្រប់គ្រង និងកិច្ចការជាច្រើនទៀត។ ដូច្នេះយើងបានរៀបចំក្របខណ្ឌកម្មវិធីសិក្សាថ្មីសម្រាប់ចំណេះទូទៅ ដោយយើងបានចាប់ផ្ដើមពង្រឹងវិធីសាស្ត្របង្រៀន ដោយមិនត្រឹមតែផ្ដោតលើចំណេះទូទៅតែមួយមុខនោះទេ ប៉ុន្តែយើងក៏ផ្ដោតលើការងារអប់រំក្រៅប្រព័ន្ធ និងការងារអប់រំកុមារមានពិការភាព និងជនជាតិដើមភាគតិចផងដែរ។ ដើម្បីពង្រឹងសមត្ថភាពនៃការបង្រៀន យើងបានដំឡើងគុណវុឌ្ឍិនៃការបណ្ដុះបណ្ដាលដល់ ១២+៤ ចាប់ពីឆ្នាំ២០២០ នេះ តទៅ ស្របតាមគោលនយោបាយស្ដីពីគ្រូបង្រៀន។ ប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនមានការកើនឡើងជិត ៣ ដង។ នៅក្នុងឆ្នាំ២០២០ ប្រាក់បៀវត្សរ៍តិចបំផុតមានចំនួន ១.២០០.០០០ រៀល សម្រាប់គ្រូបង្រៀនថ្នាក់បឋមសិក្សា។ ហើយពាក់ព័ន្ធនឹងការអប់រំពិសេស កន្លងមក យើងក៏បានផ្ដល់ជាថវិកាសម្រាប់ការបោះពុម្ពសៀវភៅ ឧបត្ថម្ភជាសម្ភារៈ ហើយនៅពេលនេះក្រសួងអប់រំបានទទួលបន្ទុកទាំងស្រុងលើការគ្រប់គ្រងវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេសទាំងប្រាំ។ ហើយតាមរយៈការបង្ហាញចំណាប់របស់អ្នកគ្រូ ណារី យើងក៏រីករាយផងដែរដែលបានឮថា យើងធ្វើត្រូវដែលរក្សាទុកក្របខណ្ឌជូនគ្រូបង្រៀន ទោះបីជាគាត់បានផ្លាស់ប្ដូរទៅបង្រៀនសាលាពិសេសក៏ដោយ។ ប៉ុន្តែយើងនឹងត្រូវបន្តដោះស្រាយជាបន្តចំពោះបញ្ហាគ្រូបង្រៀនជាពិសេសចំពោះសាលារៀនដែលមានកំណើនសិស្សជាបន្តបន្ទាប់ ដូចជា នៅក្នុងសាលារៀនទន្សាយជាដើម ដែលពេលនេះនៅក្នុងមួយថ្នាក់មានសិស្សរហូតដល់ទៅ ១៥ នាក់ ហើយដូចដែលយើងបានដឹងហើយថាការអប់រំសិស្សពិការមានការលំបាក។ ទោះបីជាយ៉ាងណាក៏ដោយ យើងនឹងខិតខំប្រឹងប្រែងដើម្បីស្វែងរកការគាំទ្រដើម្បីដោះស្រាយបញ្ហានេះ។ ដើម្បីដោះស្រាយបញ្ហានេះបាន មិនមែនភាគីក្រសួងអប់រំតែមួយនោះទេ គឺក្រសួងត្រូវពិភាក្សាជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះទៀត ឯកឧត្ដម បានលើកឡើងថា នៅក្នុងឆ្នាំ២០២០នេះ ក្រសួងនឹងផ្ដល់ក្របខណ្ឌថ្មីដល់គ្រូបង្រៀនត្រឹមតែ ៣.៦០០ នាក់តែប៉ុណ្ណោះ ដោយសារតែថវិកាមានកម្រិត។

ជាបន្ត លោកថោង រិទ្ធី ប្រធាននាយកដ្ឋានអប់រំពិសេស បានលើកឡើងថា ការងារអភិវឌ្ឍកម្មវិធីអប់រំពិសេសមិនអាចធ្វើឡើងដោយក្រសួងអប់រំតែម្នាក់ឯងបាននោះទេ។ ការចូលរួមពីភាគីពាក់ព័ន្ធគឺពិតជាសំខាន់ខ្លាំងណាស់។ ក្នុងនោះដែរ នៅថ្នាក់ជាតិ យើងមានគោលនយោបាយអប់រំពិសេស ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩-២០២៣ ដែលគោលនយោបាយនេះ គឺជាចក្ខុវិស័យមួយសម្រាប់ចង្អុលបង្ហាញដល់ថ្នាក់ក្រោមជាតិ ដូចជា ថ្នាក់មន្ទីរស្រុក-

ខណ្ឌ ជាដើម នៅក្នុងការអនុវត្តផែនការសកម្មដែលក្រសួងបានដាក់ចេញ។ លើសពីនេះទៀត នៅថ្នាក់ក្រោមជាតិ មិនអាចមានការចូលរួមតែពីមន្ទីរអប់រំស្រុក-ខណ្ឌ តែម្នាក់ឯងបាននោះទេ គឺត្រូវតែមានការចូលរួមពីមន្ទីរពាក់ព័ន្ធផងដែរ ដូចជាមន្ទីរសង្គមកិច្ច និងយុវនីតិសម្បទា មន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យបង្អែកស្រុកពាក់ព័ន្ធនឹងពិការភាព ដើម្បីស្វែងរកសេវាព្យាបាលជូនកុមារពិការ។ ហើយពាក់ព័ន្ធនឹងពិការភាពនេះផងដែរ ក្រសួងមានសហគមន៍ ក៏ដូចជា រដ្ឋអំណាចមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ សម្រាប់រៀបចំផែនការបន្សុីគ្នារវាងផែនការអប់រំបរិយាបន្ន និងផែនការវិនិយោគឃុំ-សង្កាត់។ យោងតាមបទបង្ហាញស្តីពីការអនុវត្តនៅក្នុងខេត្ត និងស្រុកគោលដៅ យើងបានមើលឃើញការអភិវឌ្ឍ និងភាពរីកចម្រើនជាច្រើនដែលកើតចេញពីការចូលរួមរបស់ភាគីជាច្រើន ដូចជា គណៈកម្មការវត្ត ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ ដូចជា អភិបាលស្រុក-ខេត្ត អភិបាលរងស្រុក-ខេត្ត ជាដើម។ ហើយចំណុចដែលសំខាន់បំផុតគឺ ដោយសារតែមានការគាំទ្រពីអាណាព្យាបាល សហគមន៍ និងមាតាបិតាសិស្ស ក្រុមការងារថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ និងថ្នាក់សាលារៀន ទើបយើងទទួលបានលទ្ធផលល្អបែបនេះ។

បន្ទាប់មកទៀត លោកស្រី នាង ផល្លា នាយិកានៃវិទ្យាស្ថានជាតិអប់រំពិសេស បានលើកឡើងថា កង្វះខាតគ្រូបង្រៀន គឺជាបញ្ហាប្រឈមមួយដែលកើតមានជាយូរមកហើយ ហើយបញ្ហាប្រឈមនេះក៏នៅតែបន្តមកទល់បច្ចុប្បន្ន ហេតុដូចនេះហើយទើបវិទ្យាស្ថានជាតិអប់រំពិសេសត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះខាតគ្រូបង្រៀនកុមារមានពិការភាព។ វិទ្យាស្ថានជាតិអប់រំពិសេស គឺជាសេណា-ធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ការបណ្តុះបណ្តាល និងវិក្រឹតការដល់គ្រូបង្រៀនសិស្សដែលមានតម្រូវការពិសេស។ វិទ្យាស្ថានជាតិអប់រំពិសេស មានផែនការផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនសិស្សមានពិការភាព។ បច្ចុប្បន្ន វិទ្យាស្ថាននេះបានផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនសិស្ស គ ថ្លង់ និងពិការភ្នែក ហើយវិទ្យាស្ថាននេះនឹងបន្តអនុវត្ត និងអភិវឌ្ឍផែនការរបស់ខ្លួនដើម្បីឈានទៅផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនសិស្សខ្សោយសតិបញ្ញា និងរៀបចំចងក្រងឯកសារដែលចាំបាច់សម្រាប់អ្នកគ្រូ លោកគ្រូ ដែលបង្រៀនសិស្សមានពិការភាព។ វិទ្យាស្ថានក៏មានមហិច្ឆិតាចងក្រងឯកសារសម្រាប់បង្រៀនសិស្សមានពិការភាពផ្សេងៗទៀតផងដែរ។ វិទ្យាស្ថានបានរៀបចំបោះពុម្ពសៀវភៅសិក្សាជាអក្សរប្រៃយ៍សម្រាប់សិស្សពិការ និងស្រាវជ្រាវភាសាសញ្ញាដើម្បីបោះពុម្ពសៀវភៅភាសាសញ្ញាដល់សិស្ស គ ថ្លង់ ឲ្យប្រើប្រាស់ ឲ្យបានទូលំទូលាយ។ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយ និងតាមរយៈបទបង្ហាញរបស់អ្នកគ្រូ ណារី យើងបានមើលឃើញថា ការបង្រៀនកុមារមានពិការភាព គឺពិបាកខ្លាំងណាស់ ដូច្នេះធនធានសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន គឺពិតជាចាំបាច់ខ្លាំងណាស់។ វិទ្យាស្ថានបានបណ្តុះបណ្តាលគរុសិស្សជំនាន់ថ្មីចំនួន ២០ នាក់ ដោយមានកិច្ចសហការពីអង្គការដៃគូ គឺអង្គការយូនីសេហ្វ ហើយវិទ្យាស្ថានបានផ្តល់វិក្រឹតការទៅដល់គ្រូចាស់ចំនួន ១៥៦ នាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នេះ។

លោកស្រី ផន សុធា បានលើកឡើងថា នាយកដ្ឋានបណ្តុះបណ្តាលគ្រូបង្រៀន បានធ្វើការងារពាក់ព័ន្ធនឹងការអប់រំបរិយាបន្ននេះចាប់តាំងពីឆ្នាំ២០០៧-២០០៨ មកម្ល៉េះ ដោយមានការគាំទ្របច្ចេកទេស

និងហិរញ្ញវត្ថុពីអង្គការដៃគូ ដោយជាដំបូង នាយកដ្ឋានបានបញ្ចូលកម្មវិធីអប់រំបញ្ចូលគ្នាទៅក្នុងកម្មវិធីបណ្តុះបណ្តាល ប៉ុន្តែមិនមែនជាមុខវិជ្ជាទេ ប៉ុន្តែក្រោយមកដោយសារតែមានគម្រោងពង្រឹកការអប់រំនៅមធ្យមសិក្សា យើងបានបង្កើតក្រុមការងារមួយដែលមានសមាសធាតុអញ្ជើញមកពីការិយាល័យអប់រំពិសេសនៃនាយកបឋមសិក្សា នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យសិក្សា និងនាយកដ្ឋានពាក់ព័ន្ធផ្សេងៗទៀត យើងបានកសាងឯកសារស្តីពី កម្មវិធីអប់រំបញ្ចូលគ្នា ហើយការអប់រំបញ្ចូលគ្នាត្រូវបានដាក់បញ្ចូលជាមុខវិជ្ជាដាច់ដោយឡែកជាផ្លូវការនៅក្នុងឆ្នាំ២០១១។ នៅក្នុងឆ្នាំ២០១៥ នាយកដ្ឋានបណ្តុះ-បណ្តាលគ្រូបង្រៀនបានអនុវត្តផែនការសកម្មភាពគ្រូបង្រៀន ដែលមានយុទ្ធសាស្ត្រចំនួន ៩ ហើយនៅក្នុងនោះមានយុទ្ធសាស្ត្រចំនួន ៤ ពាក់ព័ន្ធនឹងការអប់រំបរិយាបន្ន។ យុទ្ធសាស្ត្រទីមួយ ពាក់ព័ន្ធនឹងការជ្រើស-រើសបេក្ខជនដែលចូលរៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដែលមាននៅតាមសាលាគរុកោសល្យ មជ្ឈមណ្ឌលភូមិភាគ មត្តេយ្យមជ្ឈិម និងវិទ្យាស្ថានគរុកោសល្យ ដោយយើងបានលុបចោលនូវលក្ខខណ្ឌមួយនៅក្នុងការជ្រើសរើស ដែលលើកឡើងថា "បេក្ខជនត្រូវមានកាយសម្បទាល្អ"។ យុទ្ធសាស្ត្រមួយទៀត គឺយើងមានវគ្គវិក្រឹតការដល់លោកគ្រូ អ្នកគ្រូថ្នាក់ទីមួយនៅទូទាំងប្រទេស។ នៅក្នុងឆ្នាំ២០១៧ នាយកដ្ឋានក៏បានធ្វើការកែលម្អឯកសារជាច្រើនពាក់ព័ន្ធនឹងការអប់រំបរិយាបន្នផងដែរ។ ហើយដោយមានការគាំទ្រពីអង្គការ UNESCO នាយកដ្ឋានបានធ្វើការបកប្រែឯកសារ និងចងក្រងឯកសារនៅក្នុងបរិបទប្រទេសកម្ពុជា និងបាន upload នៅក្នុងវែបសាយត៍របស់អង្គការ អង្គការ UNESCO ជាភាសាខ្មែរផងដែរ។ យុទ្ធសាស្ត្រមួយផ្សេងទៀត គឺពាក់ព័ន្ធផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ក៏មាននិយាយអំពីការអប់រំបរិយាបន្នផងដែរ ដូចជា ការផ្តល់អន្តេវាសិកដ្ឋាន ដែលបង្កលក្ខណៈងាយស្រួលដល់សិស្សពិការ និងសិស្សក្រីក្រ ជាដើម។ បច្ចុប្បន្ន គម្រោង GPE បានជួយជួសជុល និងសាងសង់សាលាគរុកោសល្យមួយចំនួនផងដែរ។

លោកស្រី Satomi តំណាង NEP បានមានប្រសាសន៍ថា បច្ចុប្បន្ន មានអង្គការជាច្រើនបានធ្វើការពង្រឹងការអប់រំដល់ជនពិការ ដោយអង្គការមួយចំនួនបានផ្តោតលើការអប់រំបរិយាបន្ន និងថ្នាក់សមាហរណ-កម្ម និងអង្គការមួយចំនួនទៀតបានផ្តោតលើសាលាបង្រៀនឯកទេស។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចសំខាន់នៅក្នុងការអនុវត្ត គឺការជួបប្រជុំ និងចែករំលែកបទពិសោធន៍រវាងសមាជិកទាំងឡាយ ដើម្បីស្វែងយល់អំពីដំណើរការអនុវត្ត និងធ្វើការអភិវឌ្ឍបន្ថែមទៀត។ ឧទាហរណ៍៖ កន្លងមក AAR បានផ្តល់ការគាំទ្រដល់អង្គការជាច្រើន ដែលដំណើរការគម្រោងពាក់ព័ន្ធនឹងជនពិការ ដោយយើងបានធ្វើការពិភាក្សាជាមួយគ្នាដើម្បីទទួលបានទម្លាប់អនុវត្តល្អៗពីគម្រោងទាំងនោះ។ កន្លងមក យើងបានជួបប្រទះការលំបាក និងបញ្ហាប្រឈមជាច្រើននៅក្នុងការអនុវត្តគម្រោង ប៉ុន្តែយើងបានព្យាយាមពិភាក្សាជាមួយសមាជិកផ្សេងៗទៀត និងទទួលយកសំណូមពរក៏ដូចជាដំបូន្មានពីសមាជិកផ្សេងៗទៀត។ លើសពីនេះទៀត លោកស្រីក៏បានលើកឡើងផងដែរថា ការពង្រឹងសមត្ថភាពគ្រូបង្រៀនមិនគួរផ្តោតលើតែវិធីសាស្ត្រក្នុងការបង្រៀនកុមារពិការឲ្យបានល្អតែមួយមុខនោះទេ ប៉ុន្តែយើងក៏គួរតែផ្តោតលើការពង្រឹងឥរិយាបថរបស់គ្រូបង្រៀនផងដែរ ដែលឥរិយាបថនោះសំដៅលើការទទួលយកសិស្សមកគ្រប់មជ្ឈដ្ឋានទាំងអស់ឲ្យចូលរៀន និងភាពជឿជាក់ថា កុមារម្នាក់ៗ ទោះបីជាមកពីមជ្ឈដ្ឋានណាមួយក៏ដោយ ពួកគាត់

មានសមត្ថភាព និងមានឆន្ទៈនៅក្នុងការរៀនសូត្រ។ ដូច្នេះនៅពេលដែលពិភាក្សាអំពីសមត្ថភាពរបស់គ្រូបង្រៀន យើងគួរតែគិតដល់ទាំងវិធីសាស្រ្តក្នុងការបង្រៀន និងឥរិយាបថរបស់គ្រូបង្រៀន។

ឆ្លៀតក្នុងឱកាសនោះ លោក អ៊ិត រិទ្ធិ អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានមានប្រសាសន៍ថា កាលពី ២ ឆ្នាំមុន នាយកដ្ឋានបឋមសិក្សាបានបង្កើតតារាងប្រមូលទិន្នន័យអំពីពិការភាព ប៉ុន្តែដោយសារតែពុំមានការបណ្តុះបណ្តាល ទើបការប្រមូលទិន្នន័យអំពីពិការភាពនោះមានការលំបាកយ៉ាងខ្លាំង។ ប៉ុន្តែ បន្ទាប់ពីមន្ត្រីនៅក្នុងស្រុកជាច្រើននៅក្នុងខេត្តកំពង់ធំបានទទួលការបណ្តុះបណ្តាលអំពីការងារនេះ ដែលរៀបចំឡើងដោយនាយកដ្ឋានអប់រំពិសេសនាពេលថ្មីៗនេះ លោកអនុប្រធានបានមើលឃើញថា ទិន្នន័យដែលប្រមូលបាននៅលើកចុងក្រោយនេះ មានភាពត្រឹមត្រូវច្រើនជាងមុនពេលដែលមិនទាន់បានទទួលការបណ្តុះបណ្តាល។ ទន្ទឹមនឹងនោះដែរ លោកអនុប្រធានបានលើកឡើងផងដែរថា យើងគួរតែមានការបណ្តុះបណ្តាល និងការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ទៅកាន់លោកគ្រូ អ្នកគ្រូនៅតាមមូលដ្ឋាន អំពីការប្រមូលទិន្នន័យ និងការកំណត់អត្តសញ្ញាណជនពិការឲ្យបានត្រឹមត្រូវតាមប្រភេទពិការភាព ដើម្បីជួយដល់ជនពិការឲ្យបានទាន់ពេលវេលា។ លើសពីនេះទៀត នៅក្នុងឆ្នាំសិក្សា ២០១៩ នេះ មានភាពភ្ញាក់ផ្អើលមួយសម្រាប់ខេត្តកំពង់ធំ ដោយមានកុមារពិការបីនាក់ (១០០%) បានប្រឡងជាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ដែលនៅក្នុងនោះ មាននិស្សិតពិការម្នាក់កំពុងតែបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៣ នៅសាលាភូមិន្ទរដ្ឋបាលនាពេលបច្ចុប្បន្ន។ លោកអនុប្រធានបានលើកឡើងថា នេះគឺជាមោទនភាពមួយសម្រាប់ខេត្តកំពង់ធំ ហើយភាពជោគជ័យមួយនេះអាចកើតឡើងបាន ដោយសារតែមានការគាំទ្រពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាអង្គការដៃគូផងដែរ ហើយលោកអនុប្រធានក៏សូមថ្លែងអំណរគុណសម្រាប់ការគាំទ្រពីគ្រប់មជ្ឈដ្ឋានផងដែរ។

បើនិយាយដល់បញ្ហាហិរញ្ញវត្ថុវិញ ឯកឧត្តម ទេព ភិយ្យោរិទ្ធ អគ្គនាយកនៃនាយកដ្ឋានហិរញ្ញវត្ថុ បានមានប្រសាសន៍ថា ចំណាយនៅថ្នាក់ជាតិបានបែងចែកជាបួនប្រភេទ ដែលរួមមាន ចំណាយលើសកម្មភាព ចំណាយលើការបណ្តុះបណ្តាល ការចំណាយលើបេសកកម្ម និងចំណាយផ្សេងៗ។ ចាប់តាំងពីឆ្នាំ២០០៦ ដែលក្រសួងបានបង្កើតការិយាល័យអប់រំពិសេស ដែលស្ថិតនៅក្រោមនាយកដ្ឋានបឋមសិក្សា និងរហូតមកទល់ឆ្នាំ២០១៦ ដែលការិយាល័យនេះត្រូវបានផ្លាស់ប្តូរទៅជានាយកដ្ឋានអប់រំពិសេស នៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ កញ្ចប់ថវិកាសម្រាប់នាយកដ្ឋាននេះបានកើនឡើងចាប់ពីជិត ៥០.០០០ ដុល្លារ រហូតដល់ ១០០.០០០ ដុល្លារ ដែលជាថវិការដ្ឋ ប៉ុន្តែនៅមានថវិកាពីអង្គការដៃគូនានា ដែលរួមមាន អង្គការយូនីសេហ្វ និងអង្គការ UNESCO និងថវិកាពីប្រភពផ្សេងៗទៀត។ ប្រសិនបើបើយើងក្រឡេកមើលនាយកដ្ឋាអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស ក្នុងចំណោមថវិកាកន្លះលានដុល្លារដែលពួកគេទទួលបាន ថវិកាចំនួនពាក់កណ្តាល ប្រហែល ២៥០.០០០ ដុល្លារត្រូវបានវិភាជន៍ទៅលើការបណ្តុះបណ្តាលគ្រូបង្រៀន។ បើយើងមើលជារួម ការអប់រំបរិយាបន្នគឺជាវិស័យថ្មីមួយ យើងទាមទារពេលវេលាដើម្បីទទួលយក។ ដូច្នេះនៅពេលការពារថវិកាប្រចាំឆ្នាំ ប្រសិនបើយើងមានគោលនយោបាយច្បាស់លាស់ ថ្នាក់ដឹកនាំរបស់នាយកដ្ឋាន និងថ្នាក់ដឹកនាំរបស់វិទ្យាស្ថាន អាចធ្វើការការពារថវិការបស់ពួកគេបានតាមរយៈការធ្វើបទបង្ហាញថាតើហេតុអ្វីបានជាវិស័យមួយនេះមានសារៈសំខាន់។ បច្ចុប្បន្ន យើងមាន

សិស្សានុសិស្សចំនួន ១៨៤ នាក់ ហើយប្រសិនបើយើងចែកតាមចំនួនសិស្សវិញ ការចំណាយគឺមានរហូតដល់ ប្រហែល ៥.០០០ ដុល្លារក្នុងម្នាក់ (មិនរួមបញ្ចូលប្រាក់បៀវត្សរ៍គ្រូបង្រៀន)។ នៅឆ្នាំក្រោយនឹងមានការធ្វើវិមជ្ឈការការកំណត់ថវិការ ប៉ុន្តែធ្វើតែនៅក្នុងខេត្តបាត់ដំបងប៉ុណ្ណោះ ដោយក្រសួងនឹងផ្តោតលើវិស័យចំនួនបីជាមុនសិន ដែលរួមមាន ការអប់រំកុមារតូច ការអប់រំក្រៅប្រព័ន្ធ និងបឋមសិក្សា។ ដោយឡែកចំពោះបរិយាបន្ន ក្រសួងមិនទាន់បានរួមបញ្ចូលនៅឡើយទេ ដោយសារតែបញ្ហាធនធាន និងបញ្ហាបច្ចេកទេស។

## 4. កិច្ចពិភាក្សាជាក្រុម

នៅចុងបញ្ចប់នៃវេទិកាថ្នាក់ជាតិលើកទី ៨ មានកិច្ចពិភាក្សាជាក្រុមមួយត្រូវបានធ្វើឡើង ដោយអ្នកចូលរួមទាំងអស់ត្រូវបានបែងចែកជាប្រាំក្រុម។ នៅក្នុងនោះ មានក្រុមពិភាក្សាថ្នាក់ជាតិចំនួនមួយក្រុម ដែលមានសមាជិកជាមន្ត្រីមកពីនាយកដ្ឋាននានានៃក្រសួងអប់រំយុវជន និងកីឡា និងក្រុមពិភាក្សាថ្នាក់ក្រោមជាតិចំនួនបួនក្រុម ដែលត្រូវបានបែងចែក អាស្រ័យតាមខេត្តរបស់អ្នកចូលរួម។ ក្រុមទីមួយ រួមមានអ្នកចូលរួមដែលមកពីខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ចាម ត្បូងឃ្មុំ និងកំពង់ធំ។ ក្រុមទីពីរ រួមមានអ្នកចូលរួមដែលមកពីខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ ពោធិ៍សាត់ កំពង់ឆ្នាំង និងប៉ៃលិន។ ក្រុមទីបី រួមមាន អ្នកចូលរួមដែលមកពីខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប ខេត្តកោះកុង ខេត្តតាកែវ និងខេត្តកណ្តាល និងក្រុមទីបួន រួមមាន អ្នកចូលរួមដែលមកពីខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តសៀមរាប និងរាជធានីភ្នំពេញ។ ក្រុមទាំងប្រាំត្រូវពិភាក្សាគ្នាលើសំណួរចំនួនពីរ៖

- តើមានបញ្ហាប្រឈមចម្បងៗអ្វីខ្លះ ដែលអ្នកបានជួបប្រទះនៅក្នុងការអនុវត្តសកម្មភាពកសាងសមត្ថភាពរបស់គ្រូបង្រៀនលើការអប់រំបរិយាបន្ន នាពេលកន្លងមក?
- តើមានបញ្ហាប្រឈមចម្បងៗអ្វីខ្លះ ដែលអ្នកបានជួបប្រទះនៅក្នុងការអនុវត្តសកម្មភាពកសាងសមត្ថភាពគណៈគ្រប់គ្រងសាលារៀនលើការអប់រំបរិយាបន្ន នាពេលកន្លងមក?

ទន្ទឹមនឹងនោះ ក្រុមនីមួយៗ ត្រូវបានស្នើសុំឲ្យជ្រើសរើសបញ្ហាប្រឈមជាអាទិភាពចំនួន ៣ ទៅ ៥ និងផ្តល់អនុសាសន៍ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនីមួយៗ ដោយអនុសាសន៍នីមួយៗត្រូវតែមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន អាចអនុវត្តបាន និងមានពេលវេលាច្បាស់លាស់។

បន្ទាប់ពីបានពិភាក្សាគ្នារយៈពេលមួយម៉ោងពេញ ក្រុមទាំងប្រាំបានផ្តល់ចម្លើយដូចតទៅ៖

- **ក្រុមទី១៖**

| **បញ្ហាប្រឈម** | **អនុសាសន៍** |
|---|---|
| សមត្ថភាពរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅមានកម្រិត | ផ្តល់ការបណ្តុះបណ្តាល និងបំប៉នសមត្ថភាពផ្នែកអប់រំបរិយាបន្ន ដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន |
| កង្វះខាតគ្រូបង្រៀនផ្នែកអប់រំ | - ជ្រើសរើសគ្រូបង្រៀនឲ្យត្រូវតាមជំនាញ |

| | |
|---|---|
| បរិយាបន្ន | - ផ្តល់អាទិភាពដល់ជនមានពិការភាពមានជំនាញស្រាប់ ឲ្យក្លាយគ្រូបង្រៀនថ្នាក់បរិយាបន្ន<br>- ផ្តល់ការបណ្តុះបណ្តាល និងបំប៉នដល់គ្រូបង្រៀនតាមជំនាញ |
| កង្វះខាតថវិកា និងសម្ភារៈសម្រាប់គាំទ្រថ្នាក់អប់រំបរិយាបន្ន | - ក្រសួងធ្វើវិភាជន៍ថវិកាសម្រាប់គាំទ្រ<br>- ស្នើសុំឲ្យដៃគូអភិវឌ្ឍផ្តល់ការគាំទ្រដល់សកម្មភាពអប់រំបរិយាបន្ន។ |

- **ក្រុមទី២៖**
  - ការកសាងសមត្ថភាពរបស់គណៈគ្រប់គ្រងសាលារៀន

| **បញ្ហាប្រឈម** | **អនុសាសន៍** |
|---|---|
| នាយកសាលារៀនមួយចំនួនមិនទាន់យល់ច្បាស់អំពីការអប់រំបរិយាបន្ន | ចងក្រងឯកសារ និងប្រើប្រាស់ក្រុមការងារសកម្មភាពកុមារពិការដែលមានស្រាប់ (សេចក្តីណែនាំលេខ ២២) ដើម្បីផ្លាស់ប្តូរចំណេះដឹង។ |
| ការកំណត់អត្តសញ្ញាណកុមារពិការ | ប្រើប្រាស់សៀវភៅណែនាំរបស់នាយកដ្ឋាន (អពស) |
| បរិស្ថានរូបវន្ត | កែលម្អ និងច្នៃប្រឌិតសក្តានុពលទៅតាមស្ថានភាពជាក់ស្តែង |

  - ការកសាងសមត្ថភាពរបស់គ្រូបង្រៀន

| **បញ្ហាប្រឈម** | **អនុសាសន៍** |
|---|---|
| សមត្ថភាព និងការយល់ដឹងអំពីការអប់រំបរិយាបន្នរបស់គ្រូបង្គោលនៅមានកម្រិត | ការកំណត់សមាសភាពជាក់លាក់ដើម្បីទទួលបានការបំប៉ន |
| ការរើសអើងចំពោះមាតាបិតា និងសិស្សពិការ | ពន្យល់ និងផ្សព្វផ្សាយដល់ក្រុមអ្នកពាក់ព័ន្ធឲ្យយល់ច្បាស់អំពីតម្លៃនៃការអប់រំ |
| គ្រូបង្រៀនមួយចំនួនជាគ្រូបង្រៀនដែលមិនបានឆ្លងកាត់វគ្គគរុកោសល្យស្តីពីការអប់រំបរិយាបន្ន | ស្នើសុំឲ្យនាយកដ្ឋានជំនាញចុះស្រង់ស្ថិតិគ្រូបង្រៀនពិសេសនៅសាលារៀនដែលមានសិស្សពិការ |

- **ក្រុមទី៣៖**
  - ការកសាងសមត្ថភាពរបស់គណៈគ្រប់គ្រងសាលារៀន

| **បញ្ហាប្រឈម** | **អនុសាសន៍** |
|---|---|

| | |
|---|---|
| កិច្ចសហការរវាងសាលារៀន និងអ្នកពាក់ព័ន្ធនៅមានកម្រិត | បង្កើនកិច្ចសហការរវាងសាលារៀន និងអ្នកពាក់ព័ន្ធ |
| ពិបាកជ្រើសរើសគ្រូស្ម័គ្រចិត្ត និងគ្រូជំនាញ | ផ្តល់វគ្គបំប៉នខ្លីៗ និងការលើកទឹកចិត្តដល់គ្រូបង្រៀន |
| ហេដ្ឋារចនាសម្ព័ន្ធ | កសាងហេដ្ឋារចនាសម្ព័ន្ធទៅតាមប្រភេទពិការភាព |

- ការកសាងសមត្ថភាពរបស់គ្រូបង្រៀន

| **បញ្ហាប្រឈម** | **អនុសាសន៍** |
|---|---|
| កង្វះខាតថវិកា និងធនធានសម្ភារៈក្នុងការបំប៉ន | ស្នើសុំថវិកា និងធនធានសម្ភារៈ |
| ពិបាកក្នុងការរៀបចំ និងគ្រប់គ្រងថ្នាក់រៀន | ផ្តល់វគ្គបំប៉នខ្លីៗ និងផ្តល់ការលើកទឹកចិត្តដល់គ្រូកិច្ចសន្យា |
| គ្រូបង្រៀនពិបាកក្នុងការបង្រៀន និងផលិតសម្ភារៈបង្រៀនទៅតាមប្រភេទពិការភាព | រៀបចំនិយាមថ្នាក់រៀន-គ្រូបង្រៀន-សិស្ស |

- **ក្រុមទី៨៖**
  - **បញ្ហាប្រឈមក្នុងការកសាងសមត្ថភាពរបស់គ្រូបង្រៀន៖**
    - គ្រូបង្រៀនភាគច្រើនមិនទទួលបានការបណ្តុះបណ្តាលលើជំនាញអបរំបរិយាបន្ន
    - កង្វះខាតថវិកាសម្រាប់បំប៉ន ទិញ និងផលិតសម្ភារៈឧបទ្ទេសសម្រាប់បង្រៀន និងការរៀន
    - កង្វះខាតគ្រូបង្គោលដែលមានជំនាញអប់រំបរិយាបន្ន
    - ផ្ទះរបស់គ្រូបង្រៀននៅឆ្ងាយពីសាលារៀន
    - កង្វះខាតការគាំទ្រពីអ្នកពាក់ព័ន្ធ
  - **បញ្ហាប្រឈមក្នុងការកសាងសមត្ថភាពរបស់គណៈគ្រប់គ្រង៖**
    - គណៈគ្រប់គ្រងសាលារៀនមិនយល់ច្បាស់អំពីការអប់រំថ្នាក់បរិយាបន្ន
    - ពិបាកទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធ
    - នាយកសាលារៀនមិនបានសិក្សាអំពីលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការអប់រំបរិយាបន្ន
  - **អនុសាសន៍៖**
    - បណ្តុះបណ្តាលគ្រូបង្រៀន
    - បណ្តុះបណ្តាលគណៈគ្រប់គ្រង
    - ផ្តល់ថវិកាសម្រាប់ការអនុវត្ត

- **ក្រុមពិភាក្សាថ្នាក់ជាតិ៖**
    - បញ្ហាប្រឈម
        - គ្រូខ្វះជំនាញបច្ចេកទេស
        - កង្វះខាតសម្ភារៈបង្រៀន និងរៀន
        - កង្វះខាតឧបករណ៍ជំនួយ
        - កង្វះខាតសៀវភៅសិក្សា (ភាសាសញ្ញា-អក្សរប្រៃយ៍)
        - ពុំមានការចូលរួមឲ្យបានទូលំទូលាយ (សហគមន៍)
        - បរិស្ថានសាលារៀនមិនទាន់ត្រូវតាមស្តង់ដារ
        - ការផ្សព្វផ្សាយមិនទាន់បានទូលំទូលាយ
    - ដំណោះស្រាយ
        - បង្កើតក្រុមការងារបច្ចេកទេសដើម្បីចូលរួមបណ្តុះបណ្តាលបច្ចេកទេសជូនដល់លោកគ្រូ អ្នកគ្រូ
        - បណ្តុះបណ្តាលបច្ចេកទេសផលិតសម្ភារៈ
        - បង្កើនការផ្សព្វផ្សាយថ្នាក់អប់រំបរិយាបន្នឲ្យបានទូលំទូលាយ (ដល់សហគមន៍ជនបទ និងទីក្រុង)
        - គៀរគរការគាំទ្រ
        - ផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់គ្រូបង្រៀនដែលអនុវត្តផ្ទាល់
        - ធ្វើការចុះតាមដាន និងវាយតម្លៃ។